Peace Corps

# ភ្នាក់ងារ ពីសខ័រ សហរដ្ឋអាមេរិក នៅកម្ពុជា











# របាយការណ៍ប្រចាំឆ្នាំ ២០១៧

# មាតិកា


១១ឆ្នាំនៃការកសាងមិត្តភាព និងការផ្តល់សេវាកម្ម ............ ii
ទស្សនៈ និងគុណតម្លៃរបស់ភ្នាក់ងារភីសខ័រកម្ពុជា ............ iii
សារលិខិតពីនាយិកាប្រចាំប្រទេស ............ ១
ទិដ្ឋភាពទូទៅរបស់ភ្នាក់ងារភីសខ័រ ............ ២
ភ្នាក់ងារភីសខ័រប្រចាំនៅកម្ពុជា ............ ៣
ការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ............ ៤
អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្ន ............ ៥
ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស ............ ៦
សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៧ ............ ៧
ដំណើររឿងជោគជ័យលើផ្នែកអប់រំភាសាអង់គ្លេស ............ ៨
សកម្មភាពប្រចាំថ្ងៃរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ............ ១០
ការអប់រំសុខភាពសហគមន៍ ............ ១២
សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៧ ............ ១៣
ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព ............ ១៤
ជំនួយគម្រោងតូចៗ និងសមិទ្ធផលសម្រេចបាន ............ ១៦
ដំណើររឿងជោគជ័យផ្នែកជំនួយគម្រោងតូចៗ ............ ១៨
បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ ............ ២០

# ១១ឆ្នាំ
# នៃការកសាងមិត្តភាព និងការផ្ដល់សេវាកម្ម របស់ភ្នាក់ងារ ពីសខ័រកម្ពុជា

## ៥៧៣
**ចំនួនអ្នកស្ម័គ្រចិត្តដែលបានបម្រើការងារ ស្ម័គ្រចិត្តនៅក្នុងខេត្តចំនួន ១៩ នៃរាជធានីខេត្តទាំង ២៥**

## ២០១៧



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១១**

អ្នកស្ម័គ្រចិត្តពីសខ័រចំនួន៧១នាក់ ៣៤នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ៣៧នាក់ផ្នែកអប់រំសុខភាព ស្បថចូលបម្រើការងារនៅថ្ងៃទី១៥ ខែកញ្ញាឆ្នាំ២០១៧ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- ក្រចេះ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៦



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១០**

អ្នកស្ម័គ្រចិត្តពីសខ័រចំនួន៦៩នាក់ ៣៤នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ៣៥នាក់ផ្នែកអប់រំសុខភាព ស្បថចូលបម្រើការងារនៅថ្ងៃទី១៦ ខែកញ្ញាឆ្នាំ២០១៦ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៥



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៩**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៦៣នាក់ ៣៤នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៤



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៨**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៥៣នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៤នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប

## ២០១៣



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៧**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៤៦នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៧នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្ដាល
- កោះកុង
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១២



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៦**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៥៨នាក់ ២៩នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រះសីហនុ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១១



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៥**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៥៩នាក់ ៤០នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៩នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្ដាល
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១០



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៤ និងអ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពសហគមន៍ក្រុមដំបូង**

អ្នកស្ម័គ្រចិត្តពីសខ័រ ចំនួន៤៩នាក់ ៣១នាក់ផ្នែកអប់រំភាសាអង់គ្លេស និង ១៨នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

**អនុស្សរណៈយោគយល់ជាមួយ ក្រសួងសុខាភិបាល**

Peace Corps

ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១០ ដើម្បីចាប់ផ្ដើមកម្មវិធីការអប់រំសុខភាពសហគមន៍។

## ២០០៩



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៣**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន ៤២នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៩ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០០៨



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី២**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន ៣៩នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៨ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- កណ្ដាល
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០០៧



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសក្រុមទី១ ចំនួន២៩នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៧ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពត
- ព្រៃវែង
- សៀមរាប
- ស្វាយរៀង
- តាកែវ



**អ្នកស្ម័គ្រចិត្តពីសខ័រចូលគាល់ព្រះមហាក្សត្រ**

អ្នកស្ម័គ្រចិត្តពីសខ័រ និងនាយកប្រចាំប្រទេសរបស់ភ្នាក់ងារ ពីសខ័រប្រចាំកម្ពុជាចូលគាល់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី**

## ២០០៦

Peace Corps

**បើកការិយាល័យ**

ភ្នាក់ងារពីសខ័រ បើកការិយាល័យជាផ្លូវការដំបូងនៅក្នុងប្រទេសកម្ពុជា។

Peace Corps

**ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ ក្រសួងអប់រំ យុវជន និងកីឡា**

ភ្នាក់ងារពីសខ័រ ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡានៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៦ ដើម្បីចាប់ផ្ដើមកម្មវិធី ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស។



ភីសខ័រកម្ពុជាផ្ដល់នូវការបណ្ដុះបណ្ដាលតាមកម្រិតបទដ្ឋានខ្ពស់ និងផ្ដល់នូវការគាំទ្រទាំងស្រុង

បុគ្គលិកខ្មែររបស់ភីសខ័រកម្ពុជាគឺជាអ្នកធ្វើការសម្រេចចិត្តជួរមុខ និងជាអ្នកដោះស្រាយបញ្ហាទាំងឡាយ

អ្នកស្ម័គ្រចិត្តភីសខ័រមានចិត្តទូលាយ និង សុភាពរាបសារ

អ្នកស្ម័គ្រចិត្តភីសខ័រ មានសុវត្ថិភាព និងមានសុខភាពល្អ

អ្នកស្ម័គ្រចិត្តភីសខ័រ មានការតាំងចិត្តខ្ពស់ និងមុតមាំ

អ្នកស្ម័គ្រភីសខ័រចិត្តមានជំនាញ មានការទទួលខុសត្រូវ និងមានវិជ្ជាជីវៈ

អ្នកស្ម័គ្រចិត្តភីសខ័រសម្របខ្លួនជាមួយសហគមន៍បានយ៉ាងល្អ

**ទស្សនៈ:**

**អ្នកស្ម័គ្រចិត្តភីសខ័រជួយរឹតចំណងមិត្តភាពរវាងប្រជាជនកម្ពុជានិងប្រជាជនអាមេរិក**

ភីសខ័រកម្ពុជាគឺជាដៃគូដ៏ល្អរបស់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍នានាដែលយើងធ្វើការងារជាមួយ

ភីសខ័រកម្ពុជាថែរក្សា និងការពារកិត្យានុភាពរបស់ប្រជាជនកម្ពុជា និង កិត្យានុភាពរបស់ភ្នាក់ងារភីសខ័រសកល

# ទស្សនៈ និង គុណតម្លៃ របស់ភ្នាក់ងារភីសខ័រកម្ពុជា



# សារលិខិតពីនាយិកាប្រចាំប្រទេស



នាយិកាប្រចាំប្រទេសរបស់ភ្នាក់ងារភីសខ័រកម្ពុជា (រូបខាងស្តាំ) ជួបជាមួយអ្នកស្ម័គ្រចិត្តភីសខ័រ និងបុគ្គលិកមណ្ឌលសុខភាព

យើងមានកិត្តិយសនឹងបង្ហាញជូនរបាយការណ៍ប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៧របស់ភ្នាក់ងារភីសខ័រកម្ពុជា។ នៅក្នុងរបាយការណ៍នេះ លោកអ្នកនឹងឃើញមុខមាត់របស់អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រដែលបានចំណាយពេលពីរឆ្នាំក្នុងប្រទេសកម្ពុជា ដោយបានរស់នៅជាមួយគ្រួសារខ្មែរ បង្រៀនភាសាអង់គ្លេសនៅតាមសាលាជនបទ និងធ្វើការនៅតាមមណ្ឌលសុខភាពក្នុងសហគមន៍ ដែលកិច្ចការទាំងអស់នេះគឺជាសេវាកម្មដែលពួកគេបានផ្តល់ជូន។

អ្នកស្ម័គ្រចិត្តមានការតាំងចិត្ត និងការលះបង់ខ្ពស់ ដើម្បីនាំទៅរកភាពជោគជ័យ ប៉ុន្តែបទពិសោធន៍របស់ពួកគេមិនអាចទទួលជោគជ័យបានទេ ប្រសិនបើគ្មានការស្វាគមន៍ និងការគាំទ្រពីសំណាក់ប្រជាជនកម្ពុជាទេនោះ។ របាយការណ៍នេះមិនត្រឹមតែរៀបរាប់ពីអ្នកស្ម័គ្រចិត្តរបស់យើងប៉ុណ្ណោះទេ តែក៏រៀបរាប់អំពីប្រជាជនកម្ពុជាទាំងអស់ ដែលបានធ្វើឲ្យសេវាកម្មរបស់អ្នកស្ម័គ្រចិត្តប្រព្រឹត្តិទៅដោយរលូនផងដែរ។

ឆ្នាំនេះគឺជាឆ្នាំទី១១ហើយដែលភ្នាក់ងារភីសខ័រកម្ពុជាបានដំណើរការនៅក្នុងប្រទេសកម្ពុជាដែលមានអ្នកស្ម័គ្រចិត្តជាង៥៧០នាក់ និងធ្វើការនៅតាមបណ្តាខេត្តចំនួន១៩។ យើងសូមសម្តែងនូវអំណរគុណចំពោះប្រទេសដែលជាម្ចាស់ផ្ទះគឺរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើឲ្យកិច្ចការនេះដំណើរការបានតាមរយៈការផ្តល់លទ្ធភាពធ្វើការជាដៃគូក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។

ភ្នាក់ងារភីសខ័រកម្ពុជាបានលើកកម្ពស់ការបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តរបស់យើងក្នុងការអភិវឌ្ឍជំនាញភាសា ការយល់ដឹងផ្នែកវប្បធម៌ និងចំណេះដឹងបច្ចេកទេសរបស់ខ្លួន តាមរយៈនេះ ពួកគេអាចចែករំលែកជំនាញដែលពួកគេមានប្រកបដោយប្រសិទ្ធភាពនិងក្លាយខ្លួនជាសមាជិកមួយរូបរបស់សហគមន៍នោះផ្ទាល់។ ទាល់តែពួកគេយល់ដឹងច្បាស់ពីសហគមន៍នោះទើបពួកគេអាចចែករំលែក និងធ្វើកិច្ចការទាំងនោះបាន។

អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាលើកកម្ពស់ទំនាក់ទំនង ដោយផ្សារភ្ជាប់ចំណងទាក់ទងគ្នារវាងប្រជាជនដែលមានស្ថានភាពវប្បធម៌ សេដ្ឋកិច្ច និងសង្គមផ្សេងគ្នា។ បេសកកម្មរបស់ភ្នាក់ងារភីសខ័រគឺដើម្បីលើកកម្ពស់សន្តិភាពក្នុងពិភពលោក និងកសាងមិត្តភាព ហើយអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រទាំងអស់បំពេញបេសកកម្មនេះតាមរយៈការធ្វើការងារស្ម័គ្រចិត្តនៅក្នុងសហគមន៍ដើម្បីជួយរឹតចំណងមិត្តភាពរវាងគ្នានឹងគ្នាអោយកាន់តែល្អប្រសើឡើងថែមទៀត។

គ្មានពាក្យពេចន៍ និងតួលេខណាមួយអាចបកស្រាយ និងកត់ត្រាពីផលវិជ្ជមានដែលអ្នកស្ម័គ្រចិត្តទាំងនេះទទួលបាននោះទេ ប៉ុន្តែនៅក្នុងរបាយការណ៍នេះ យើងចែករំលែកនូវរឿងរ៉ាវមួយចំនួនអំពីអ្វីដែលអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាបានរៀនសូត្រពីសហគមន៍នានាក្នុងប្រទេសកម្ពុជា និងអំពីអ្វីដែលអ្នកស្ម័គ្រចិត្តទាំងនោះបានចែករំលែកជាមួយសហគមន៍ជាការតបស្នងវិញ។



ផល្លា អាល់បឺតសុន
*នាយិកាប្រចាំប្រទេស*
*អតីតអ្នកស្ម័គ្រចិត្តភីសខ័រ*
*នៅប្រទេសហុងឌូរ៉ាស់ ឆ្នាំ១៩៩២-១៩៩៤*

# ទិដ្ឋភាពទូទៅរបស់ភ្នាក់ងារ ភីសខ័រ

ភ្នាក់ងារ ភីសខ័រ បញ្ជូនជនជាតិអាមេរិកល្អៗប្រកបដោយចំណេះដឹង ដែលជាតំណាងអោយសហរដ្ឋអាមេរិក ទៅក្រៅប្រទេស ដើម្បីជួយដោះស្រាយបញ្ហាដែលជាតម្រូវការបន្ទាន់របស់ប្រជាជនទូទាំងពិភពលោក ។ អ្នកស្ម័គ្រចិត្តទាំងអស់ ធ្វើការនៅតាមសហគមន៍ដើម្បីបង្កើតដំណោះស្រាយប្រកបដោយនិរន្តរភាព ដែលឆ្លើយតបនឹងបញ្ហាផ្សេងៗក្នុងវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន ។ តាមរយៈការបម្រើសេវាកម្មរបស់ពួកគេ អ្នកស្ម័គ្រចិត្តទាំងអស់ទទួលបាននូវការយល់ដឹងអំពីវប្បធម៌ ពិសេសជាមួយនឹងការប្ដេជ្ញាចិត្តក្នុងមួយជីវិតរបស់គេក្នុងការបម្រើការងារដែលអាចអោយគេស្ថិតក្នុងតួនាទីមួយដែលនាំអោយពួកគេទទួលបានភាពជោគជ័យក្នុងសង្គមបច្ចុប្បន្ននេះ ។

ភ្នាក់ងារនេះបានចាប់ផ្ដើមតាំងពីឆ្នាំ១៩៦០មកម្លេះ នៅពេលដែលអតីតសមាជិកព្រឹទ្ធសភាលោក John F. Kennedy បាននាំនិស្សិតនៅសកលវិទ្យាល័យ Michigan អោយបម្រើប្រទេសរបស់ពួកគេ ដោយការរស់នៅ និងធ្វើការនៅក្នុងតំបន់ដាច់ស្រយាលមួយចំនួននៃពិភពលោក ។ លោកបានបណ្ដុះអោយមានចលនាក្នុងចំណោមយុវជនអាមេរិកដែលបានជំរុញប្រទេសជាតិទាំងមូល និងបានដឹកនាំរហូតដល់មានការបង្កើតឡើងនូវភ្នាក់ងារ ភីសខ័រ ។ នៅក្នុងពិភពលោកមួយដែលពោរពេញទៅដោយការផ្លាស់ប្ដូរ ភ្នាក់ងារនេះ បានក្លាយជាភ្នាក់ងារឆ្នើមដែលប្រកបដោយភាពស្វាហាប់ និងដំណើរឆ្ពោះទៅមុខក្នុងវិស័យសេវាកម្ម អន្តរជាតិ ដោយសារគំនិតច្នៃប្រឌិតថ្មី និងសេចក្ដីអាណិតមេត្តារបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ បេសកកម្មដំបូងរបស់ភ្នាក់ងារនេះគឺនៅតែមិនផ្លាស់ប្ដូរ៖

## បេសកកម្មរបស់ភ្នាក់ងារ ភីសខ័រ

ដើម្បីបង្កើនមិត្តភាព និងសន្តិភាពនៅលើពិភពលោក ដោយបំពេញនូវគោលដៅចំនួនបី៖

១ *ផ្ដល់អ្នកស្ម័គ្រចិត្តទាំងបុរស និងស្ត្រី ដែលបានទទួលការបណ្ដុះបណ្ដាល ទៅចូលរួមជួយប្រជាជននៅក្នុងបណ្ដាប្រទេសដែលចាប់អារម្មណ៍លើភ្នាក់ងារ ភីសខ័រ ។*

២ *ជួយអ្នកស្ម័គ្រចិត្តអាមេរិកអោយមានការយល់ដឹងកាន់តែប្រសើរអំពីប្រជាជនទាំងឡាយដែលពួកគេធ្វើការជាមួយ ។*

៣ *ជួយបង្កើនការយល់ដឹងរបស់ប្រជាជននៅជុំវិញពិភពលោកអោយបានយល់ដឹងកាន់តែប្រសើរអំពីជនជាតិអាមេរិក។*



*លោកប្រធានាធិបតី John F. Kennedy និងនាយកភ្នាក់ងារ ភីសខ័រ លោក Sargent Shriver ស្វាគមន៍អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ទៅកាន់ប្រទេស Tanganyika និង Ghana នៅក្នុងការិយាល័យរបស់លោកប្រធានាធិបតី ។*



*លោកប្រធានាធិបតី John F. Kennedy ស្វាគមន៍អ្នកស្ម័គ្រចិត្តនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៦១ ។*

### ប្រវត្តិ

| | |
|---|---|
| ត្រូវបានបង្កើតជាផ្លូវការ | ថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៦១ |
| ជនជាតិអាមេរិកដែលបានបម្រើការងារ | ២៣០,០០០ |
| ប្រទេសសាមីដែលត្រូវបានបម្រើមកដល់បច្ចុប្បន្ន | ១៤១ |

### ភ្នាក់ងារភីសខ័រ បច្ចុប្បន្ន៖

| | |
|---|---|
| ប្រទេសម្ចាស់ផ្ទះ | ៦៥ |
| អ្នកស្ម័គ្រចិត្ត និងសិក្ខាកាម | ៧,៣៧៦ |
| យេនឌ័រ | ស្ត្រី ៦៣% និង បុរស ៣៧% |
| ស្ថានភាពគ្រួសារ | នៅលីវ ៩៨% និងរៀបការហើយ ២% |
| ជនជាតិភាគតិច | ៣២% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |
| អាយុជាមធ្យម | ២៨ |
| អ្នកស្ម័គ្រដែលមានអាយុលើសពី៥០ឆ្នាំ | ៦% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |




*ផែនទីបង្ហាញពីខេត្តទាំងឡាយដែលមានអ្នកស្ម័គ្រចិត្ត ភីសខ័រ បម្រើការងារចាប់តាំងពីកម្មវិធីចាប់ផ្ដើមនៅក្នុងឆ្នាំ ២០០៧ មក*

# ភ្នាក់ងារភីសខ័រ ប្រចាំនៅកម្ពុជា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញភ្នាក់ងារភីសខ័រ អោយបើកដំណើរការកម្មវិធីក្នុងប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៩២ ហើយកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរត្រូវបានចុះហត្ថលេខានៅឆ្នាំ ១៩៩៤ ។ ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពនយោបាយមិនមានស្ថេរភាពគ្រប់គ្រាន់សម្រាប់អោយអ្នកស្ម័គ្រចិត្តចូលមកកម្ពុជាក្នុងពេលនោះ ។ នៅឆ្នាំ២០០៤ ការពិភាក្សាគ្នាអំពីការបង្កើតអោយមានភ្នាក់ងារ ភីសខ័រកម្ពុជាបានបន្តទៀត ហើយភ្នាក់ងារ ភីសខ័របានស្វាគមន៍អ្នកស្ម័គ្រចិត្តក្រុមទីមួយមកកាន់ប្រទេសកម្ពុជា នៅឆ្នាំ ២០០៧ ។

មនុស្សម្នាក់ៗដែលត្រូវបម្រើការជាអ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ ត្រូវបានជ្រើសរើសតាមរយៈដំណើរការដាក់ពាក្យសុំដែលពោរពេញទៅដោយការប្រកួតប្រជែង ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ មានអាយុចាប់ពី ២២ ដល់ ៧៥ឆ្នាំ ហើយតំណាងអោយក្រុមជនជាតិ និងសាសន៍ផ្សេងៗគ្នា ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ ឬ ខ្ពស់ជាងនេះ ។ អ្នកស្ម័គ្រចិត្តមកប្រទេសកម្ពុជាដើម្បីប្រើប្រាស់ជំនាញនិងចំណេះដឹងរបស់ពួកគេដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស តាមរយៈសកម្មភាពផ្ទាល់នៅតាមសហគមន៍ ។ បន្ទាប់ពីបានមកដល់ប្រទេសកម្ពុជា អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ ត្រូវឆ្លងកាត់វគ្គបណ្ដុះបណ្ដាលជាច្រើនលើផ្នែកភាសា វប្បធម៌ សុខភាព សុវត្ថិភាព និងបច្ចេកទេស ។ ក្នុងកំឡុងពេលនៃការបំពេញសេវាកម្មរបស់ពួកគេ ភ្នាក់ងារភីសខ័រនឹងផ្ដល់ឱកាសអោយមានវគ្គបណ្ដុះបណ្ដាលដល់អ្នកស្ម័គ្រចិត្តនិងគ្រូបង្រៀនដៃគូរបស់ពួកគេដើម្បីពង្រឹងជំនាញបច្ចេកទេស និងភាសា ។

អ្នកស្ម័គ្រចិត្តរស់នៅជាមួយគ្រួសារខ្មែរ ដែលមានជីវភាពប្រហាក់ប្រហែលនឹងពលរដ្ឋកម្ពុជានៅក្នុងសហគមន៍របស់ពួកគេ។ ពួកគេធ្វើការងារជាមួយប្រជាជនកម្ពុជា ដើម្បីជួយពួកគេអោយអនុវត្តការងារដែលមានប្រសិទ្ធភាពដើម្បីឈានទៅរកអនាគតមួយដ៏ល្អប្រសើរជាងមុនសម្រាប់សហគមន៍ក៏ដូចជាប្រទេសកម្ពុជាទាំងមូល ។

## គម្រោងក្នុងពេលបច្ចុប្បន្នះ

**ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស**

**ការអប់រំសុខភាពសហគមន៍**




*ចំនួនអ្នកស្ម័គ្រចិត្តក្នុងឆ្នាំនិមួយៗចាប់តាំងពីឆ្នាំ២០០៧*




*ភាគរយនៃអ្នកស្ម័គ្រចិត្តក្នុងកម្មវិធីអប់រំភាសាអង់គ្លេស និងអប់រំសុខភាព មកដល់ពេលបច្ចុប្បន្ន*

# ការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា



*នៅឆ្នាំ២០១៥ នាយិកាភ្នាក់ងារភីស ខ័រ Carrie Hessler-Radelet ជួបជាមួយ ឯកឧត្តម វេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល*

ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាគឺជាស្នូលនៃកិច្ចការរបស់ភ្នាក់ងារភីសខ័រកម្ពុជា។ ភាពជាដៃគូរបស់យើងចាប់ផ្តើមឡើងជាមួយក្រសួងអប់រំ យុវជន និងកីឡាតាមរយៈអនុស្សារណៈនៃការយោគយល់ក្នុងឆ្នាំ២០០៧ ក្នុងការបញ្ជូនអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាទៅកាន់វិទ្យាល័យមួយចំនួនដើម្បីផ្តល់ការគាំទ្រក្នុងកិច្ចការបង្រៀនភាសាអង់គ្លេស។ ភាពជាដៃគូរបស់យើងបានពង្រីកខ្លួនដល់ក្រសួងសុខាភិបាលក្នុងឆ្នាំ២០១០ តាមរយៈអនុស្សារណៈនៃការយោគយល់ដើម្បីបញ្ជូនអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាទៅមណ្ឌលសុខភាពនានាដែលពួកគេផ្តល់ការអប់រំផ្នែកសុខាភិបាល។ ភាពជាដៃគូទាំងនេះផ្តល់លទ្ធភាពឲ្យមានកម្មវិធីជាច្រើនដើម្បីដំណើរកិច្ចការងារដល់ប្រជាជនកម្ពុជារហូតដល់១សែននាក់។

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល បង្ហាញទិសដៅជាយុទ្ធសាស្រ្តដល់ភ្នាក់ងារភីសខ័រកម្ពុជា និងការចូលទៅដល់ទីតាំងភូមិសាស្ត្រនានាក្នុងប្រទេស។ មន្ត្រីថ្នាក់ស្រុក និងថ្នាក់ខេត្តក្នុងក្រសួងទាំងពីរនេះបានជួយកំណត់ទីតាំងដែលអ្នកស្ម័គ្រចិត្តត្រូវបំពេញការងារ។ ប្រធានមណ្ឌលសុខភាព និងនាយកនាយិកាសាលាជាអ្នកដឹកនាំអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជា។

ក្រសួងការបរទេស និងសហប្រត្តិបត្តិការអន្តរជាតិផ្តល់ការអនុញ្ញាតដល់ភ្នាក់ងារភីសខ័រអោយធ្វើការក្នុងប្រទេសកម្ពុជា និងផ្តល់ទិដ្ឋាការសម្រាប់អ្នកស្ម័គ្រចិត្តយើងទាំងអស់។ ក្រសួងមហាផ្ទៃ ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំបានជួយជ្រោមជ្រែងយើងក្នុងការរក្សាសុវត្ថិភាព និងផ្តល់ជូនការគាំទ្រក្នុងករណីបន្ទាន់ដល់អ្នកស្ម័គ្រចិត្តរបស់យើង។

ភ្នាក់ងារភីសខ័រកម្ពុជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតសម្រាប់ការណែនាំ បដិសណ្ឋារកិច្ច និងការលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។




*នៅឆ្នាំ២០១៥ នាយិកាភ្នាក់ងារ ភីសខ័រ Carrie Hessler-Radelet ជួបជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*



អ្នកស្ម័គ្រចិត្ត ពីសខ័រ ក្រុមទី១១

# អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្ន

## ស្ថិតិឆ្នាំ ២០១៧

| | | | |
|---|---|---|---|
| ចំនួនអ្នកស្ម័គ្រចិត្ត | ១១២នាក់៖ បម្រើការងារនៅក្នុង រាជធានីខេត្តចំនួន ១៦ | ចាប់ពីអាយុ ២០ ដល់២៩ឆ្នាំ៖ ៩១%<br>ចាប់ពីអាយុ ៣០ ដល់ ៣៩ឆ្នាំ៖ ៥%<br>ចាប់ពីអាយុ ៤០ ដល់ ៦២ឆ្នាំ៖ ៤% | អាយុ |
| គម្រោង | ៥១នាក់៖ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស<br>៦១នាក់៖ ការអប់រំសុខភាពសហគមន៍ | អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្នមកពីរដ្ឋចំនួន ៣៨ នៃរដ្ឋទាំង៥០ របស់សហរដ្ឋអាមេរិក | រដ្ឋនៃសហរដ្ឋអាមេរិក |
| យេនឌ័រ | ៧០នាក់៖ ស្ត្រី<br>៤២នាក់៖ បុរស | | |

## ការបណ្តុះបណ្តាលមុនពេលបំពេញការងារស្ម័គ្រចិត្ត

| | | |
|---|---|---|
| **សិក្សាភាសាខ្មែរ** | : | ១៦២ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| | : | ១៨៥ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាព |
| **សិក្សផ្នែកបច្ចេកទេសការងារជាមួយដៃគូជនជាតិខ្មែរ** | : | ៦០ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| | : | ៤៤ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាព |
| **សិក្សាវប្បធម៌ខ្មែរ** | : | ៣៣ម៉ោង |
| **អនុវត្តការងារ** | : | ៤៦ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| | : | ៤០ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាព |
| **ការរស់នៅប្រចាំថ្ងៃ** | : | រស់នៅជាមួយគ្រួសារខ្មែរ |



អ្នកស្ម័គ្រចិត្តពីសខ័រផ្នែកអប់រំភាសាអង់គ្លេសចូលរួមវគ្គបណ្តុះបណ្តាល នៅការិយាល័យ ពីសខ័រ



អ្នកស្ម័គ្រចិត្តពីសខ័រផ្នែកអប់រំសុខភាពសហគមន៍ ចូលរួមវគ្គបណ្តុះបណ្តាលនៅការិយាល័យពីសខ័រ







# ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស

គម្រោងបណ្ដុះបណ្ដាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស បាននឹងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៧។ គម្រោងនេះបានធ្វើការដើម្បីអភិវឌ្ឍជំនាញគិតដោយវិភាគ និងភាសាអង់គ្លេសដល់សិស្សានុសិស្ស គ្រូបង្រៀន និងប្រជាជនក្នុងសហគមន៍ ដើម្បីជួយអោយពួកគេទទួលបានឱកាសសិក្សារៀនសូត្របន្ថែម ឱកាសការងារ ក៏ដូចជាឱកាសផ្ទាល់ខ្លួនផងដែរ។

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសបង្រៀននៅតាមវិទ្យាល័យ និងសាលាគរុកោសល្យ ។ ដូចដែលបានស្នើសុំដោយក្រសួងអប់រំ យុវជន និងកីឡា អ្នកស្ម័គ្រចិត្តបង្រៀនរួមគ្នាជាមួយគ្រូជនជាតិខ្មែរ។ ការធ្វើបែបនេះមិនត្រឹមតែផ្ដល់ផលប្រយោជន៍ដល់សិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើនសមត្ថភាពភាសារបស់គ្រូបង្រៀន ព្រមទាំងបង្កើនជំនាញបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនរបស់ពួកគេផងដែរ។ តាមរយៈការបង្រៀនជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្តអាចចែករំលែកវិធីសាស្ត្រក្នុងការបង្រៀនបែបទំនើប ជួយរៀបចំនិងបង្រៀនមេរៀន បង្កើនជំនាញភាសាអង់គ្លេសសម្រាប់ការប្រាស្រ័យទាក់ទង និងណែនាំអោយស្គាល់ពីបច្ចេកទេសផ្សេងៗក្នុងការគ្រប់គ្រងថ្នាក់រៀនអោយមានប្រសិទ្ធភាព។

អ្នកស្ម័គ្រចិត្តក៏បង្កើត និងបង្កើនធនធានសម្រាប់ការរៀនសូត្រ និងការបង្រៀនផងដែរដែលរួមមានដូចជាការណែនាំនូវបច្ចេកវិទ្យាថ្មីៗ។ តាំងពីឆ្នាំ២០០៧ មានអ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសចំនួន៣៦៥នាក់ បានបំពេញការងារស្ម័គ្រចិត្តនៅប្រទេសកម្ពុជា។

### គោលដៅរបស់គម្រោង៖

- ▲ បង្កើនវិធីសាស្ត្របង្រៀន
- ▲ បង្កើនភាពជោគជ័យរបស់សិស្ស

### សកម្មភាពរបស់គម្រោង៖

- ▲ បង្រៀនរួមគ្នាជាមួយគ្រូដៃគូជាជនជាតិខ្មែរក្នុងថ្នាក់រៀន
- ▲ បង្កើតកិច្ចតែងការបង្រៀន និងសម្ភារៈបង្រៀន ដែលប្រើប្រាស់វិធីសាស្ត្រទំនាក់ទំនងក្នុងការបង្រៀនភាសាអង់គ្លេស
- ▲ សម្របសម្រួលសកម្មភាពសិក្សាក្រៅម៉ោងរបស់សិស្សានុសិស្ស និងបង្កើតក្លឹបសិក្សា
- ▲ បង្កើតបណ្ណាល័យ និងមណ្ឌលធនធានសំរាប់ការសិក្សា

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧

## គោលដៅទី ១៖ បង្កើនវិធីសាស្ត្របង្រៀន

សាស្ត្រាចារ្យនឹងបង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេស និងអនុវត្តវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល។

### បង្កើនវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌលដល់សាស្ត្រាចារ្យ

**៤៤%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់បច្ចេកទេសថ្មីៗរបស់ពួកគេក្នុងការបង្រៀនសិស្ស។

**៤០%**
ចំនួនគ្រូដែលបានបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងថ្នាក់រៀនអោយកាន់តែមានប្រសិទ្ធភាព។

**៤១%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់ការវាយតម្លៃថ្នាក់រៀនដែលមានមូលដ្ឋានរបស់ខ្លួនក្នុងការតាមដាន និងព័ត៌មានវឌ្ឍនភាពរបស់សិស្ស។

**១០០%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់ធនធានសិក្សាឬសម្ភារៈថ្នាក់រៀនរបស់ពួកគេដោយការបង្កើតការលើកកម្ពស់ ឬគ្រប់គ្រងសម្ភារៈដូចជាកិច្ចតែងការមេរៀន ផ្ទាំងរូបភាព ឯកសារ សៀវភៅបណ្ណាល័យឬ សម្ភារៈផ្សេងទៀតដែលគាំទ្រដល់ការសិក្សា។

### បង្កើនភាពស្ទាត់ជំនាញខាងទំនាក់ទំនងជាភាសាអង់គ្លេសដល់សាស្ត្រាចារ្យ

**៦២%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់បច្ចេកទេសថ្មីៗ សម្រាប់ការបង្រៀនភាសាអង់គ្លេស។

**៤២%**
ចំនួនគ្រូដែលបានបង្កើនការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាភាសាអង់គ្លេស។

**៤៣%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់ភាសាអង់គ្លេសនៅពេលបង្រៀនក្នុងថ្នាក់។

### បង្កើនវិធីសាស្ត្របង្រៀនដល់គរុសិស្ស

**៤២%**
ចំនួនគរុសិស្សដែលបង្កើនវិធីបង្រៀនសិស្សបែបមជ្ឈមណ្ឌល។

**៥២%**
ចំនួនគរុសិស្សដែលបង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេយ៉ាងហោចណាស់ ១០% ដោយការវាយតម្លៃតាមឧបករណ៍វាយតម្លៃជាផ្លូវការ។

**៤៣%**
ចំនួនគរុសិស្សដែលបានបង្កើតអោយប្រសើរឡើងឬគ្រប់គ្រងសម្ភារៈឧបទេសដូចជា ផ្ទាំងរូបភាព ឯកសារ កិច្ចតែងការ ឬសម្ភារៈដែលគាំទ្រការសិក្សាថ្នាក់រៀនផ្សេងទៀត។

## គោលដៅទី ២៖ បង្កើនភាពជោគជ័យដល់សិស្ស

សិស្សានុសិស្ស ឬយុវជន នឹងបង្កើនសមត្ថភាពភាសាអង់គ្លេស និងអភិវឌ្ឍជំនាញលើភាពជាអ្នកដឹកនាំតាមរយៈការសិក្សាភាសាអង់គ្លេសតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីសិក្សាបន្ថែម។

### បង្កើនចំណេះដឹងសិស្សតាមរយៈការចូលរួមសកម្មភាពផ្សេងៗ និងផ្តល់ជំនាញភាពជាអ្នកដឹកនាំតាមរយៈកម្មវិធីសិក្សាបន្ថែម

**១,៤៩៨**
ចំនួនសិស្សដែលបានបង្ហាញភាពជាអ្នកដឹកនាំនៅក្នុងថ្នាក់និងក្រៅថ្នាក់តាមរយៈសកម្មភាពដូចជាការបង្រៀនពីមិត្តភក្តិ ឬ ធ្វើលំហាត់ជំនួយបន្ថែម។

### បង្កើនចំណេះដឹងរបស់សិស្សតាមរយៈការចូលរួមសកម្មភាពសិក្សាក្នុងថ្នាក់

**៥,០៤៧**
ចំនួនសិស្សដែលបានបង្ហាញពីការកើនឡើងនូវចំណេះដឹងភាសាអង់គ្លេស ។

**៤,១១៩**
ចំនួនសិស្សដែលបានបង្កើន/បង្ហាញពីការជឿជាក់លើខ្លួនឯង និងការលើកទឹកចិត្តខ្លួនតាមរយៈការចូលរួមសកម្មភាពក្នុងថ្នាក់ក្លឹបសិក្សាតូចៗតាមសាលា ឬ បោះជំរំសិក្សា។

### ពង្រីកការប្រើប្រាស់បណ្ណាល័យនិង/ឬការប្រើប្រាស់ និងធនធានបច្ចេកវិទ្យាទំនាក់ទំនង និងពត៌មានវិទ្យា (ICT)

**៤,៥២២**
ចំនួនសិស្ស ដែលបានចូលប្រើប្រាស់បណ្ណាល័យដើម្បីអាន ឬ ប្រើប្រាស់ធនធានបច្ចេកវិទ្យា ឬធនធានផ្សេងៗទៀត។

# ដំណើររឿងជោគជ័យលើផ្នែកអប់រំភាសាអង់គ្លេស

## សិស្សថ្នាក់ភាសាអង់គ្លេស ឈ្មោះ នោរា និង កាន

*អ្នកស្ម័គ្រចិត្ត ចេម ដាយើ និងលោកគ្រូ ខូយ វណ្ណៈ*
*ខេត្តបន្ទាយមានជ័យ*



*សិស្សហាត់សមការធ្វើបទបង្ហាញដែលពួកគេរៀបចំ*

សិស្សពីររូប នោរា និង កាន សិក្សានៅវិទ្យាល័យហ៊ុនសែនមង្គលបុរី ក្នុងខេត្តបន្ទាយមានជ័យបានចងចាំជានិច្ចនៅពេលដែលគ្រូរបស់ខ្លួនឈ្មោះ វណ្ណៈ ដែលធ្វើការជាមួយអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាមួយរូបឈ្មោះ ចេម ធ្វើការបែងចែកថ្នាក់ជាក្រុមតូចៗ។ កាលពីដំបូង សមាជិកក្រុមទាំងអស់មានអារម្មណ៍ថ្មីខុសប្លែក ក្រោយមក ទើបពួកគេដឹងថាការបែងចែកក្រុមដែលមានសិស្សកម្រិតខុសគ្នា រួចបញ្ចូលគ្នាធ្វើឲ្យពួកគេរៀនសូត្របានច្រើន។ ក្នុងក្រុមនីមួយៗ សិស្សកម្រិតខ្ពស់អាចជួយសិស្សដែលទើបនឹងចូលរៀនដំបូង។ សិស្សកម្រិតខ្ពស់ដូចជានោរាក៏ទទួលបាននូវការបង្រៀនថ្នាក់ភាសាកម្រិតខ្ពស់ដែលស៊ីគ្នាទៅនិងកម្រិតរបស់ខ្លួន ក្នុងនោះសិស្សដែលមានកម្រិតខ្ពស់ទទួលបាននូវតួនាទីដឹកនាំតាមរយៈការផ្តល់ជំនួយដល់អ្នកផ្សេងទៀតនៅក្នុងក្រុម។ ក្រុមតូចក៏អនុញ្ញាតឲ្យសិស្សមួយរូបដូចជា កាន ដែលទាមទារឲ្យមានការគាំទ្របន្ថែម ដើម្បីទទួលបាននូវការណែនាំតាមរយៈការធ្វើការងារផ្ទាល់ក្នុងកម្រិតមួយ ដែលសិស្សអាចទទួលយកបាន។ សិស្សទាំងពីរក្រុមទទួលបានផលប្រយោជន៍ដូចគ្នាពីយុទ្ធសាស្ត្រនេះ។

ឆាប់ៗខាងមុខនេះ សិស្សទាំងអស់គ្នានឹងមើលឃើញពីផលប្រយោជន៍ និងបានបង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេសតាមរយៈការរៀនក្នុងថ្នាក់។ ក្រោយមក វណ្ណៈ និង ចេម ក៏សម្រេចចិត្តបង្កើតឱកាសថ្មីៗជាច្រើនសម្រាប់សិស្សដើម្បីអនុវត្តនូវអ្វីដែលពួកគេបានរៀន។ ការសរសេរសំបុត្រឆ្លើយឆ្លងគ្នារវាងសិស្សអាមេរិកាំង និងសិស្សខ្មែរបានអនុញ្ញាតឲ្យ

> *“នៅពេលខ្ញុំសរសេរសំបុត្រមួយនេះ វាជាលើកទីមួយដែលខ្ញុំបង្ហាញឲ្យជនបរទេសដឹងអំពីប្រទេសរបស់ខ្ញុំ។ ឥឡូវនេះ ពេលដែលខ្ញុំទៅលេងខេត្តសៀមរាប ខ្ញុំតែងតែនិយាយទៅកាន់ជនបរទេស និងប្រាប់ពួកគេអំពីប្រទេសរបស់ខ្ញុំ។ ការសរសេរទៅកាន់សិស្សបរទេសម្នាក់នៅអាមេរិកដោយរៀបរាប់អំពីប្រទេសកម្ពុជា បានជួយឲ្យខ្ញុំមានមោទនភាពអំពីវប្បធម៌របស់ខ្ញុំ។*
> *– នោរា”*

សិស្សអាចភ្ជាប់ទំនាក់ទំនងជាមួយសិស្សជីវវិទ្យាមួយចំនួនមកពីទីក្រុង ឡរ៉ែល រដ្ឋមីឈីហ្គែន។ តាមរយៈសំបុត្រទាំងនេះ នោរា និង កាន និងសិស្សផ្សេងទៀតក្នុងថ្នាក់ អានជាភាសាអង់គ្លេសអំពីអ្វីៗមួយចំនួន ដូចជាប្រព័ន្ធបរិស្ថានព្រៃឈើនៅរដ្ឋមីឈីគែន និងកីឡាបាល់ទាត់អាមេរិកាំង។ ក្រោយមកពួកគេបានសរសេរឆ្លើយឆ្លងគ្នាជាភាសាអង់គ្លេស ដោយចែករំលែកព័ត៌មានជាមួយសិស្សក្នុងរដ្ឋមីឈីគែន អំពីវប្បធម៌ និងភាសាខ្មែរ ជាពិសេសប្រវត្តិសាស្ត្រអង្គរវត្ត ពិធីបុណ្យ និង ថ្ងៃបុណ្យឈប់សម្រាករបស់ប្រជាជនកម្ពុជា។

ការរួមបញ្ចូលអត្ថបទសរសេរជាភាសាដើម ដូចជាការសរសេរសំបុត្រជាដើម ទៅក្នុងថ្នាក់រៀនភាសា បានបណ្តុះឲ្យមានការជម្រុញទឹកចិត្តដល់សិស្សានុសិស្សផ្សេងៗ។ នេះជាអ្វីមួយដែលត្រូវបានមើលឃើញជាពិសេសក្នុងបណ្តាសិស្សានុសិស្សទាំងឡាយដែលមិនធ្លាប់មានចំណាប់អារម្មណ៍ក្នុងការរៀនសូត្រសោះពីមុនមក។ ខាន់ គឺជាសិស្សប្រុស រៀនថ្នាក់ទី១០(ខ)។ ឆ្នាំមុន គាត់មិនដែលបង្ហាញចំណាប់អារម្មណ៍ក្នុងការរៀនភាសាអង់គ្លេសទេ ប៉ុន្តែឥឡូវនេះ គាត់គឺជាចំណែកមួយក្នុងក្លឹបភាសាអង់គ្លេសប្រចាំសប្តាហ៍របស់សាលា។


*ការពិភាក្សាអំពីការថតវីដេអូនៃការធ្វើបទបង្ហាញដើម្បីផ្ញើទៅអាមេរិក*

# ដំណើររឿងជោគជ័យលើផ្នែកអប់រំតាមសាលាអង្គលស

## ក្លឹបសិក្សាអំពី ការរៀនរស់នៅជាមួយគ្នា

*អ្នកស្ម័គ្រចិត្ត មេហ្គែន បោនឌី និងអ្នកគ្រូ សូ សំបូរី*
*ខេត្តកំពត*

កម្មវិធីក្លឹបសិក្សា *"រៀនរស់នៅជាមួយគ្នា - Learning to Live Together Olympics"* ផ្តល់ជាកម្លាំងចិត្តដល់សិស្សានុសិស្សក្នុងថ្នាក់តាមរយៈបច្ចេកទេសបង្រៀនសិស្សមជ្ឈមណ្ឌល ហេតុដូច្នេះ ការរៀនពិតជាធ្វើឲ្យសិស្សសប្បាយរីករាយក្នុងចិត្ត។ ក្លឹបសិក្សានេះទទួលបានថវិកាចំនួន៧៧០ដុល្លារ ដែលត្រូវបានផ្តល់តាមរយៈវិភាគទានសហគមន៍មានតម្លៃប្រមាណ ២៦១៨ដុល្លារ។

> *“ខ្ញុំ និងអ្នកគ្រូ សូ សំបូរី ដែលជាគ្រូបង្រៀនម្នាក់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ខេត្តបានពិភាក្សាគ្នាពីវិធីក្នុងការលើកទឹកចិត្តសិស្ស និងធ្វើឲ្យការរៀនសូត្រមាន ភាពសប្បាយរីករាយ។ ក្នុងអំឡុងពេលនៃការពិភាក្សាប្រចាំថ្ងៃរបស់យើង យើងរកឃើញគំនិតមួយ ដើម្បីបង្កើតឲ្យមានការប្រកួតប្រជែងតាមរយៈចំណេះដឹងសាកលលោក និងការបង្កើត ក្រុម។ គំនិតនេះបានរីកលូតលាស់ និងបានប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល ក្លឹបសិក្សា និងការប្រកួតប្រជែងដែលមានរយៈពេលកន្លះថ្ងៃ។*
> *– មេហ្គែន”*

ក្លឹបសិក្សានេះចាប់ផ្តើមឡើងដោយការបង្កើតវគ្គបណ្តុះបណ្តាលជាច្រើនសម្រាប់សិក្ខាកាមដែលជាគ្រូបឋមសិក្សា ដើម្បីរៀនបន្ថែមទៀតអំពីពិភពលោក នៅពេលជាមួយគ្នានោះដែរ សិក្ខាកាមទាំងនោះបានអភិវឌ្ឍជំនាញអំពីស្មារតីនៃការធ្វើការជាក្រុម។ ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមដែលជាគ្រូ បង្រៀនបានបង្រៀនព័ត៌មានដល់សិស្សថ្នាក់ទី៦ មួយដងក្នុងមួយសប្តាហ៍ សម្រាប់រយៈពេល ១៥សប្តាហ៍។



*លោកនាយកសាលាប្រកាសចែករង្វាន់ដល់ក្រុមទទួលជ័យលាភី*

ក្រោយពីរយៈពេលនេះ កម្មវិធីប្រកួតប្រជែងត្រូវបានរៀបចំឡើង។ រសៀលថ្ងៃមួយ ក្នុងខែសីហា សិស្សថ្នាក់ទី៦ទាំងអស់ក្រោមការដឹកនាំរបស់សិក្ខាកាមដែលជាគ្រូបង្រៀនត្រូវបានបែងចែកជាក្រុមផ្សេងៗពីគ្នា រួចត្រូវធ្វើសកម្មភាព និងកិច្ចការជាច្រើនទាក់ទងនិងការសិក្សា។ អស់រយៈពេល៤ខែ សិស្សជាង១០០នាក់បានចូលរួមកម្មវិធីនេះ។

លើសពីនេះ មេហ្គែន និងអ្នកគ្រូ សូ សំបូរី បានធ្វើកិច្ចការជាមួយគ្រូមួយចំនួនដើម្បីគូរផែនទីពិភពលោកមួយផ្ទាំងនៅលើជញ្ជាំងសាលារៀន។ តាមរយៈវិភាគទានសហគមន៍ចំនួន ៧៧% នៃថវិកាគម្រោងទាំងអស់ ពួកគេចាប់ផ្តើមទិញសម្ភារៈសម្រាប់គូរផែនទី។ សិក្ខាកាមដែលជាគ្រូបង្រៀនគ្រោងនឹងគូរផ្ទាំងគំនូរផែនទីនៅលើជញ្ជាំងនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ខេត្ត។

ក្លឹបសិក្សានេះ ជួយលើកកម្ពស់ចំណេះដឹងទូទៅជាសាកលរបស់សិក្ខាកាមដែលជាគ្រូបបង្រៀន កសាងជំនាញធ្វើការងារជាក្រុម លើកកម្ពស់កម្លាំងចិត្តក្នុងការរៀននិងបង្រៀន និងបង្ហាញសិក្ខាកាមដែលជាគ្រូបង្រៀនថា ការបង្រៀនគឺមានភាពសប្បាយរីករាយ។



*សមាជិកក្លឹបសិក្សាទាំងអស់*

# សកម្មភាពប្រចាំថ្ងៃរបស់

## បង្រៀនភាសាអង់គ្លេស ក្លឹបសិក្សាភាសាអង់គ្លេស លើកកម្ពស់ស្ត្រី អប់រំសុខភាពសហគមន៍


















# អ្នកស្ម័គ្រចិត្តពីសខ័រកម្ពុជា

*វាស់សញ្ញាជីវិត ក្លឹបសិល្បៈ កសាងទំនាក់ទំនងជាមួយសហគមន៍ និងសកម្មភាពច្រើនទៀត*




















# ការអប់រំសុខភាពសហគមន៍

នៅឆ្នាំ ២០០៩ ដោយសារមានការស្នើសុំពីក្រសួងសុខាភិបាល ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជាបានពង្រីកសកម្មភាពរបស់ខ្លួនដោយការចាប់ផ្តើមគម្រោងអប់រំសុខភាពសហគមន៍ ។ គោលបំណងនៃគម្រោងនេះ ដើម្បីជួយសហគមន៍ និងប្រជាជនកម្ពុជា ជាពិសេសស្ត្រី និងកុមារក្នុងការលើកកម្ពស់សុខភាពនិងសុខុមាលភាពទូទៅក៏ដូចជាការបង្កើនសមត្ថភាពរបស់ពួកគេដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងសុខភាព។ អ្នកស្ម័គ្រចិត្តភីសខ័រធ្វើការជាមួយបុគ្គលិកមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ និងសាលារៀនផ្សេងៗ ដើម្បីកសាងសមត្ថភាពរបស់ប្រជាជនក្នុងសហគមន៍អោយចេះឆ្លើយតបនឹងតម្រូវការផ្នែកសុខភាពរបស់ពួកគេ។មានអ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពចំនួន២០៨នាក់បានបំពេញការងារតាំងពីឆ្នាំ២០១០មកម្លេះ។

## គោលដៅរបស់គម្រោង៖

- ▲ សុខភាពមាតា និង កុមារ
- ▲ ការប្រព្រឹត្តដែលនាំឲ្យមានសុខភាពល្អ

## សកម្មភាពរបស់គម្រោង៖

- ▲ ធ្វើការអប់រំសុខភាពនៅមណ្ឌលសុខភាពសហគមន៍ និងតាមរយៈការចុះតាមផ្ទះ
- ▲ លើកកម្ពស់ការអនុវត្តអាហារូបត្ថម្ភជាវិជ្ជមានតាមរយៈសួនបន្លែតាមផ្ទះនិងសហគមន៍ និងការបង្ហាញពីការចំអិននិងផ្តល់អាហារដល់កូន
- ▲ លើកកម្ពស់ការពិនិត្យសុខភាពម្តាយមុននិងក្រោយពេលសម្រាល ការចាក់ថ្នាំបង្ការ និងការធ្វើផែនការគ្រួសារនៅទូទាំងសហគមន៍
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីបញ្ហាអនាម័យនិងទឹកស្អាត ដូចជាការលាងដៃអោយបានត្រឹមត្រូវ ការទប់ស្កាត់និងការព្យាបាលជម្ងឺរាគរូស ការបាត់បង់ជាតិទឹក និងការព្យាបាលដែលសមស្រប ក៏ដូចជាការរក្សាទុកទឹកស្អាតផងដែរ
- ▲ ដឹកនាំប្រជាជនអោយចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចជាការធ្វើលំហាត់ប្រាណជាក្រុម ការបង្ហាញពីការចំអិនអាហារដែលនាំអោយមានសុខភាពល្អ ពត៌មានអំពីការប្រឆាំងនឹងការជក់បារី និង  យុទ្ធនាការបង្កើនការយល់ដឹងអំពីគ្រឿងស្រវឹង និងថ្នាំញៀន
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីសុខភាពបន្តពូជ

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧

## គោលដៅទី ១៖ សុខភាពមាតា និង កុមារ

ប្រជាជនក្នុងសហគមន៍នឹងបង្កើនចំណេះដឹង និងជំនាញ និងទទួលយកនូវការអនុវត្តន៍ល្អក្នុងការថែទាំសុខភាពមាតា និងទារក។

### ការពិនិត្យផ្ទៃពោះមុនសម្រាល និងការសម្រាលកូន

**៨,៨២៦**
ចំនួនម្តាយមានផ្ទៃពោះបានទទួលការអប់រំអំពីសារៈសំខាន់នៃការពិនិត្យផ្ទៃពោះ ការថែទាំក្រោយសម្រាល ការចាក់ថ្នាំបង្ការ ផែនការគ្រួសារ និង ការសម្រាលកូន។

**៤,៣៨៤**
ចំនួនស្ត្រីដែលដឹងយ៉ាងហោច៤ ឬច្រើននៃសញ្ញាគ្រោះថ្នាក់អំឡុងពេលមានផ្ទៃពោះ ហើយដែលត្រូវទៅរកការសង្គ្រោះជាបន្ទាន់ពីគ្រូពេទ្យ។

**២,២០៥**
ចំនួនប្រជាពលរដ្ឋដែលបានរៀនជាបុគ្គល ឬជាក្រុម អំពីមធ្យោបាយពន្យារកំណើត។

**២,២៩៣**
ចំនួនស្ត្រីដែលមានកូនអាយុក្រោម១២ខែ ប្រាប់ថាគាត់បានទៅពិនិត្យផ្ទៃពោះ៤ដង ឬច្រើនជាងបួនដងអំឡុងពេលមានផ្ទៃពោះ។

### អាហារូបត្ថម្ភ

**៨,៤៨៩**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីសុខភាពកុមារ និងអាហារូបត្ថម្ភតាមរយៈកម្មវិធីសុខភាពដែលទ្រទ្រង់ដោយរដ្ឋាភិបាលអាមេរិក។

**៤,២៥៦**
ចំនួនអាណាព្យាបាល ឬស្ត្រីដែលបានទទួលការអប់រំពីអ្នកស្ម័គ្រចិត្ត ឬដៃគូដែលបានរកឃើញសកម្មភាពមួយ ឬក៏ច្រើនជាងមួយដើម្បីបង្ការគ្រួសារមិនឲ្យកង្វះអាហារូបត្ថម្ភ។

**៨,០៩៨**
ចំនួនកុមារដែលមានអាយុពី៦ដល់ ៥៩ខែ មានប័ណ្ណសុខភាពដែលបានថ្លឹងទម្ងន់យ៉ាងហោចបានមួយដងកាលពី៣ខែមុន។

**៤៧%**
ចំនួនស្ត្រីដែលបង្ហាញថាពួកគេចេះអំពីរបៀបរៀបចំចំអិនអាហារបំប៉នសម្រាប់កុមារបានត្រឹមត្រូវ។

**៨៨%**
ចំនួនគ្រួសារដែលត្រូវបានបណ្តុះបណ្តាលដោយអ្នកស្ម័គ្រចិត្តបានរាយការណ៍ថាទទួលបានអាហារស្រស់ៗក្នុងរយៈពេល៦ខែបន្ទាប់ពីបានធ្វើសួនបន្លែ។

### អនាម័យ និង ទឹកស្អាត

**៦០៣**
ចំនួនមនុស្សដែលអាចបង្ហាញថាពួកគាត់ចេះពីរបៀបធ្វើឲ្យទឹកស្អាតសម្រាប់ប្រើប្រាស់។

**៩៥៧**
ចំនួនមនុស្សដែលបានរៀន/ទទួលការអប់រំអំពីរបៀបធ្វើឲ្យទឹកស្អាតនិងរក្សាទុកដាក់ទឹកសម្រាប់ផឹកនិង សម្រាប់ដាំស្លបានត្រឹមត្រូវ។

**៥,៥៤៥**
ចំនួនមនុស្សដែលស្គាល់ពេលវេលាសំខាន់៣ ឬអាចច្រើនជាង៣ដែលពួកគាត់ត្រូវលាងសម្អាតដៃ។

## គោលដៅទី ២៖ ការប្រព្រឹត្តដែលនាំឲ្យមានសុខភាពល្អ

ប្រជាពលរដ្ឋក្នុងសហគមន៍នឹងបានរីកចម្រើនកាន់តែប្រសើរថែមទៀត នូវបំណិនជីវិត ហើយនឹងប្រព្រឹត្តទៅតាមទម្លាប់ដែលនាំមកនូវសុខភាពល្អ។

### ជម្ងឺមិនឆ្លង

**៤,៩៨៧**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីជម្ងឺមិនឆ្លង និង ការកាត់បន្ថយកត្តាដែលនាំឲ្យមានគ្រោះថ្នាក់។

**១,៩៧៤**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីភាពគ្រោះថ្នាក់នៃការផឹកស្រា និង ការប្រើប្រាស់សារធាតុញៀនផ្សេងៗ។

**៦,២៥៨**
ចំនួនមនុស្សពេញវ័យ ដែលបានទទួលការអប់រំ អំពីរបបអាហារប្រចាំថ្ងៃ ដែលមានសារៈសំខាន់សម្រាប់សុខភាព។

**១,៦២៥**
ចំនួនមនុស្សដែលទទួលការអប់រំអំពីកត្តាបង្កគ្រោះថ្នាក់នៃជម្ងឺឆ្លងដែលទាក់ទងនឹងការប្រើប្រាស់ថ្នាំជក់ និងអំពីការឈប់ប្រើប្រាស់ថ្នាំជក់។

**៥៣៧**
ចំនួនដងនៃការហាត់ប្រាណ ដែលរៀបចំដោយអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ និង ដៃគូការងារ។

**២,៥៦៣**
ចំនួនមនុស្សអាចរកឃើញពីវិធីហាត់ប្រាណ២ ឬច្រើនយ៉ាង ដើម្បីឲ្យក្លាយជាទម្លាប់ប្រចាំថ្ងៃរបស់ពួកគេ។

### សុខភាពបន្តពូជ

**១,៩២១**
ចំនួនមនុស្សដែលដឹងពីវិធីយ៉ាងតិចពីរអំពីការការពារកុំអោយមានផ្ទៃពោះ ឬការពារកុំអោយឆ្លងជម្ងឺកាមរោគ។

**៥០៧**
ចំនួនមនុស្សដែលចេះពីរបៀបប្រើប្រាស់ស្រោមអនាម័យបានយ៉ាងត្រឹមត្រូវ។

# ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព

## យុទ្ធនាការគ្មានការបន្ទោបង់តាមទីវាលនៅភូមិសណ្ដាន់

*អ្នកស្ម័គ្រចិត្ត បើន រស និងអ្នកស្រី ចាន់ សាវេត*
*ខេត្តកំពង់ធំ*

ភូមិសណ្ដាន់ស្ថិតក្នុងចម្ងាយ៨០គីឡូម៉ែត្រភាគឥសានពីទីរួមខេត្តកំពង់ធំ ស្ថិតនៅផ្នែកខាងត្បូងព្រៃឡង់ ហើយភូមិនេះគឺជាសហគមន៍ជីសកម្មមួយដែលមានផ្ទះចំនួន១១០ខ្នង។ ទីនោះគឺជាទីតាំងរបស់ការិយាល័យស្រុក មណ្ឌលសុខភាព វិទ្យាល័យ និងការិយាល័យរដ្ឋបាលជាច្រើន ហើយឆាប់ៗខាងមុខនេះទីនោះនឹងក្លាយជាសហគមន៍ដំបូងគេដែលគ្មានការបន្ទោបង់តាមទីវាល។



សាវេតបង្ហាញផែនទីសហគមន៍របស់គាត់

អ្នកដែលដឹកនាំកិច្ចការងារនេះគឺ ចាន់ សាវេត ដែលជាសមាជិកក្រុមទ្រទ្រង់សុខភាពភូមិ និងជាអ្នកភូមិសណ្ដាន់។ សាវេត បានរៀបរាប់ពីយុទ្ធនាការណ៍គ្មានការបន្ទោបង់តាមទីវាល ថា ៖

> “ *ដំបូងឡើយ យើងគ្មានផែនការធ្វើបែបនេះទេ។ កាលពីខែមីនាកន្លងទៅ ខ្ញុំបានចូលរួមវគ្គបណ្ដុះបណ្ដាលរបស់ភ្នាក់ងារភីសខ័រ រួចខ្ញុំក៏ចង់បង្កើតកិច្ចការមួយទាក់ទងនឹងផ្នែកអនាម័យ ស្ទូនបន្លែ និងអណ្ដូងទឹក។*
> *– សាវេត* ”

កិច្ចប្រជុំថ្នាក់ភូមិរកឃើញថា អនាម័យគឺជាបញ្ហាអាទិភាពសម្រាប់សហគមន៍ ហើយកិច្ចប្រជុំក្រោយៗមកទៀតបាននាំទៅរកការបង្កើតយុទ្ធនាការគ្មានការបន្ទោបង់តាមទីវាលសម្រាប់ស្រុកសណ្ដាន់។ សាវេត និង បើន បានធ្វើការជាមួយអ្នកសាងសង់ក្នុងភូមិដើម្បីផ្ដល់ការរចនាប្លង់បង្គន់អនាម័យតម្លៃថោកទៅដល់ក្រុមគ្រួសារចំនួន ៣២ ដែលកំពុងប្រឈមមុខនូវកង្វះអនាម័យជាខ្លាំង ព្រមទាំងបានរៀបចំវគ្គអប់រំជាច្រើនស្ដីអំពីការផ្សាភ្ជាប់គ្នារវាងអនាម័យ និងសុខភាព។

ផ្លាកសញ្ញាសម្រាប់ផ្ទះនីមួយៗទូទាំងភូមិសណ្ដាន់នឹងបង្ហាញឲ្យឃើញនូវការប្ដេជ្ញាចិត្តរបស់សហគមន៍ក្នុងការថែរក្សាស្ថានភាព នៃភាពគ្មានការបន្ទោបង់តាមទីវាល។

សាវេត បានពន្យល់ថា “គ្រាន់តែបង្គន់អនាម័យសង់រួចភ្លាម អ្នកភូមិលែងបន្ទោបង់តាមទីវាលទៀតហើយ។ មានន័យថា មេរោគលែងឆ្លងតាមរុយ និងវត្ថុអ្វីផ្សេងៗទៀតហើយ។ អ្នកភូមិនឹងមិនចំណាយប្រាក់កាសច្រើនក្នុងការទទួលបានការថែទាំពីមណ្ឌលសុខភាព និងគ្លីនីកនានាទៀតទេ”។

តាមរយៈតួនាទីរបស់ខ្លួនជាអ្នករៀបចំសហគមន៍ សាវេត ចាប់ផ្ដើមមានការទទួលខុសត្រូវថ្មីក្នុងភូមិរបស់គាត់ និងទទួលបាននូវជំនាញថ្មីៗដែលគាត់មានបំណងបន្តប្រើប្រាស់តទៅមុខទៀត។

គាត់បាននិយាយថា “វាមិនចាំបាច់តែភូមិរបស់ខ្ញុំទេប្រសិនបើយើងធ្វើគម្រោងនេះនៅភូមិផ្សេងទៀត ខ្ញុំនឹងធ្វើការជាមួយសហគមន៍នោះដែរ។ ខ្ញុំអាចគិតពីគម្រោងនោះ និង បង្កើតបានជាគំនិតជាច្រើនព្រោះខ្ញុំបានធ្វើគម្រោងនេះម្ដងរួចទៅហើយ”។



សាវេតជួបប្រជុំជាមួយប្រជាជនក្នុងសហគមន៍

# ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព

## សុខភាពតាមរយៈការជឿជាក់

*អ្នកស្ម័គ្រចិត្ត ខេលស៊ី ស្វាវែល និងលោកគ្រូពេទ្យ ពេជ្រ វិត*
*ខេត្តតាកែវ*

នៅពេលខ្ញុំមកដល់មណ្ឌលសុខភាពជាលើកដំបូង កាលនោះ ខ្ញុំមានអារម្មណ៍អន្ទះសារ ហើយចេះនិយាយភាសាខ្មែរបន្តិចបន្តួច លោកគ្រូពេទ្យឈ្មោះ ពេជ្រ វិត គឺជាមិត្តភក្តិ និងជាគ្រូបង្រៀនដំបូងរបស់ខ្ញុំ។ បុគ្គលិកផ្សេងទៀតមិនចេះពីរបៀបឆ្លើយឆ្លងជាមួយខ្ញុំទេ ហើយក៏មិនដឹងពីតួនាទីរបស់ខ្ញុំដែរ ហើយខ្ញុំទៀតសោតក៏មិនដឹងពីតួនាទីរបស់ពួកគាត់ដែរ។ ម្យ៉ាងទៀត ពួកយើងមានការខ្មាសអៀននឹងគ្នាអស់រយៈពេលជាច្រើនខែ។



*ខេលស៊ី ចូលរួមប្រជុំជាមួយបុគ្គលិកមណ្ឌលសុខភាព*

> *“ថាមពល ការលើកទឹកចិត្ត និងបំណងប្រាថ្នារបស់លោកគ្រូ វិត ធ្វើឲ្យគាត់ក្លាយជាដៃគូដ៏សាកសមសម្រាប់ខ្ញុំ។ គាត់គឺជាអ្នកទំនាក់ទំនងដ៏ល្អម្នាក់ប្រចាំសហគមន៍ ជាអ្នកជួយលើកកម្ពស់គម្រោង ជាអ្នកមើលថវិកា ជាអ្នកអប់រំសុខភាព ជាមិត្តភក្តិ និងជាអ្នកបង្ហាត់បង្រៀនក្នុងសហគមន៍អស់រយៈពេលជាច្រើនឆ្នាំ។*
>
> *– ខេលស៊ី”*

ទោះជាយ៉ាងណា វិត ជឿជាក់លើខ្ញុំ និងមានជំនឿថាប្រសិនបើខ្ញុំជឿគាត់និងចូលរួមជាមួយគាត់ពេលចុះទៅអប់រំអំពីការចាក់ថ្នាំបង្ការតាមសហគមន៍ ជួបជាមួយមន្ត្រីនៅមូលដ្ឋាន និងអ្នកជំងឺនៅតាមផ្ទះ និងព្យាយាមអង្កេតមើលកិច្ចការផ្សេងៗក្នុងមណ្ឌលសុខភាពទាំងមូល ខ្ញុំនឹងដឹងពីការបង្កើតតួនាទីសម្រាប់ខ្លួនឯង។ គាត់និយាយពិតជាត្រឹមត្រូវណាស់។ គាត់ហៅខ្ញុំថាជា “ដៃគូ” របស់គាត់នៅពេលយើងចុះទៅអប់រំអំពីការចាក់ថ្នាំបង្ការព្រោះខ្ញុំជួយកិច្ចការគាត់រួមមាន៖ លើកទឹកចិត្តម្តាយៗឲ្យចេះថ្លឹងទម្ងន់ទារក និងរក្សាកំណត់ហេតុទម្ងន់ទារក ដោយកត់ត្រាចូលក្នុងប័ណ្ណលូតលាស់របស់ទារក និងពិនិត្យមើលកាលវិភាគសម្រាប់ចាក់ថ្នាំបង្ការ ផ្តល់ការអប់រំផ្នែកអាហារបម្រងរាងកាយនិងសុខភាពទៅតាមអាយុរបស់ទារក និងធ្វើយ៉ាងណាឲ្យមាតាទាំងឡាយដឹងពីពេលវេលាដែលកូនរបស់ខ្លួនត្រូវទទួលការចាក់ថ្នាំបន្ទាប់។

កិច្ចការយើងទាំងអស់គ្នាមិនកំណត់ត្រឹមតែក្នុងមណ្ឌលសុខភាព ឬការចាក់ថ្នាំបង្ការប៉ុណ្ណោះទេ។ កាលពីខែមុន វិត និង ខ្ញុំបានទៅមើលមជ្ឈមណ្ឌលសន្តិសុខម្ហូបអាហាររបស់ភ្នាក់ងារភីសខ័រដូចជាការបណ្តុះបណ្តាលអំពីការដាំបន្លែធម្មជាតិ។ ថ្មីៗនេះយើងមានគម្រោងសួនធម្មជាតិមួយដែលមេភូមិចំនួនដប់រូបនឹងចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីការធ្វើជីធម្មជាតិ និងការផលិតថ្នាំសម្លាប់សត្វល្អិតបែបធម្មជាតិ។ បន្ទាប់មក មេភូមិទាំងនោះនឹងដឹកនាំវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះពេលដែលគាត់ត្រលប់ទៅភូមិរបស់គាត់រៀងៗខ្លួនវិញ។ ម្យ៉ាងទៀត ដើម្បីគាំទ្រគម្រោងសាងសង់អណ្តូងទឹកដើម្បីលើកកម្ពស់ការលាងសម្អាតដៃក្នុងបណ្តាបុគ្គលិកពេទ្យរបស់មណ្ឌលសុខភាព វិត បានគាំទ្រ និងពន្យល់ជាបន្តបន្ទាប់អំពីសារៈសំខាន់នៃការកសាងអណ្តូងទឹក និងការអប់រំសុខភាព។



*ខេលស៊ី និងលោកគ្រូ វិត នៅមណ្ឌលសុខភាព*

# ជំនួយគម្រោងតូចៗ និង សមិទ្ធផលសម្រេចបាន

កម្មវិធីជំនួយគម្រោងតូចៗរបស់ភ្នាក់ងារភីសខ័រកម្ពុជាអាចផ្តល់ឱកាសដល់អ្នកស្ម័គ្រចិត្ត និងដៃគូរបស់ពួកគេអោយទទួលបានថវិកា និងធនធានផ្សេងៗក្នុងការគាំទ្រគំនិតផ្តួចផ្តើម និងគម្រោងដែលស្របតាមតម្រូវការអាទិភាពសម្រាប់សហគមន៍របស់ពួកគេ និងរួមចំណែកដល់សមិទ្ធផលនៃទិសដៅអភិវឌ្ឍន៍របស់កម្ពុជា។ គម្រោងទាំងនោះផ្តោតលើវិស័យជាច្រើនរួមមាន សុខភាពមាតា អនាម័យទឹកស្អាត និងសុខុមាលភាព សន្តិសុខស្បៀងអាហារ អាហារបំប៉ន ភាពជាអ្នកដឹកនាំសម្រាប់យុវជន និងការអភិវឌ្ឍន៍ធនធានសាលារៀន។ មុននឹងអភិវឌ្ឍគម្រោង អ្នកស្ម័គ្រចិត្តទាំងអស់និងដៃគូដែលជាជនជាតិខ្មែរទទួលបានការបណ្តុះបណ្តាលរយៈពេល២៤ម៉ោងស្តីពីការរៀបចំនិងគ្រប់គ្រងគម្រោងសម្របសម្រួលដោយបុគ្គលិករបស់ភ្នាក់ងារភីសខ័រកម្ពុជា។

ក្នុងឆ្នាំ២០១៧ គម្រោងថវិកាខ្នាតតូចរបស់ភ្នាក់ងារភីសខ័រកម្ពុជាបានផ្តល់ថវិកា ចំនួន១១ម៉ឺនដុល្លាដល់គម្រោងចំនួន៤៩។ គម្រោងទាំងអស់ត្រូវបានតាក់តែង និងគ្រប់គ្រងដោយសហដៃគូរបស់សហគមន៍ និងអ្នកស្ម័គ្រចិត្តដោយផ្តោតលើការកសាងសមត្ថភាព និងស្ថេរភាព។ ក្នុងអំឡុងឆ្នាំ២០១៧ ថវិការបស់ភ្នាក់ងារភីសខ័រកម្ពុជាបានសាយភាយ ដោយផ្ទាល់ដល់អ្នកទទួលបានផលប្រយោជន៍ដែលជាជនជាតិខ្មែរចំនួន១៥០០០នាក់ និងដោយប្រយោលដល់ប្រជាជនជាង៤៥០០០នាក់ផ្សេងទៀត។ តាមរយៈគម្រោងថវិកាដែលរៀបចំឡើងដោយអ្នកស្ម័គ្រចិត្តនិងដៃគូរបស់ពួកគេសមត្ថភាពរបស់អ្នកផ្តល់សេវាកម្មច្រើនជាង៧៥០នាក់ត្រូវបានបង្កើនក្នុងវិស័យសុខាភិបាលនិងវិស័យអប់រំទូទាំងខេត្តចំនួន១៧។



*សិស្សសាលាលាងសម្អាតដៃរបស់គេយ៉ាងរីករាយជាមួយនឹងទឹកស្អាតនៅកន្លែងលាងដៃដែលសាងសង់ដោយអ្នកស្ម័គ្រចិត្តភីសខ័រ និងសហគមន៍*

## អនាម័យទឹកស្អាត និងសុខុមាលភាព (WASH)

- ▲ អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាធ្វើការជាមួយដៃគូសហគមន៍ដើម្បីលើកកម្ពស់អនាម័យ និងលក្ខខណ្ឌសុខុមាលភាពក្នុងសហគមន៍របស់ពួកគេតាមរយៈការស្ថាបនាបរិក្ខារផ្សេងៗនិងការអប់រំទាក់ទងនឹងប្រធានបទមួយចំនួនដូចជាការលាងសម្អាតដៃ ការថែទាំនិងការផ្ទុកទឹកស្អាត និងផលប៉ះពាល់នៃការបន្ទោបង់តាមទីវាល។
- ▲ តាមរយៈគម្រោងទាំងនេះ ទីកន្លែងសម្អាតដៃ បង្គន់អនាម័យ និងប្រព័ន្ធចម្រោះទឹកស្អាតត្រូវបានតម្លើងនៅមណ្ឌលសុខភាព តាមផ្ទះ និងនៅតាមសាលានានា។
- ▲ គម្រោងទាំងនេះតែងតែផ្តល់លទ្ធភាពក្នុងការទទួលបាននូវប្រភពទឹកស្អាតតាមរយៈការសាងសង់អណ្តូងទឹក និងអាងស្តុកទឹក។
- ▲ គម្រោង WASH មានគោលបំណងកាត់បន្ថយគ្រោះថ្នាក់នៃជំងឺឆ្លងតាមរយៈទឹកក្នុងសហគមន៍ទាំងមូល ដែលនាំទៅរកការរស់នៅយូរអង្វែងនិងសុខភាពល្អសម្រាប់សហគមន៍ទាំងមូល។

### សមិទ្ធផល

- *សាងសង់ប្រភពទឹកស្អាត : ១១*
- *ជួសជុលបង្គន់អនាម័យ : ២៦*
- *សាងសង់បង្គន់អនាម័យ : ១១៩*
- *សាងសង់កន្លែងលាងសម្អាតដៃ : ១០៣*
- *ចែកចាយធុងចម្រោះទឹកស្អាត : ៤៣*

# ជំនួយគម្រោងតូចៗ និង សមិទ្ធផលសម្រេចបាន

## សួនបន្លែសម្រាប់អាហារូបត្ថម្ភ

- អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាធ្វើការជាមួយដៃគូសហគមន៍ដើម្បីបង្កើតសួនដំណាំនៅតាមមណ្ឌលសុខភាព តាមផ្ទះ និងតាមសាលារៀនដើម្បីលើកកម្ពស់ការទទួលទានអាហារប្រកបដោយជីវជាតិភាពក្នុងបណ្តាសមាជិកក្នុងសហគមន៍។ គម្រោងទាំងនេះក៏រួមបញ្ចូលទាំងការអប់រំផ្នែកម្ហូបអាហារ និងសារៈសំខាន់នៃម្ហូបអាហារ ប្រកបដោយជីវជាតិសុខភាពសម្រាប់កុមារ និងមនុស្សពេញវ័យ។
- សួនបន្លែនៅតាមសាលារៀនត្រូវបានបង្កើតនិងថែទាំដោយសិស្សដើម្បីផ្តល់ឱកាសអោយពួកគេទទួលបាននូវការពិសោធផ្ទាល់ដែលបន្ថែមទៅនឹងអ្វីដែលសិស្សទាំងនោះបានរៀនក្នុងម៉ោងកសិកម្ម។ សិស្សនិងគ្រូរៀនស្វែងយល់ពីការអនុវត្តនៃការដាំដុះបន្លែធម្មជាតិ និងយកបន្លែនោះទៅផ្ទះដើម្បីប្រើប្រាស់។
- សួនបន្លែនៅតាមផ្ទះត្រូវបានបង្កើតឡើងដើម្បីបង្កើនភាពសម្បូរបែបនៃរបបអាហារសម្រាប់គ្រួសារ ជាពិសេសសម្រាប់កុមារអាយុក្រោម៥ឆ្នាំ។ គ្រួសារទទួលបានការបណ្តុះបណ្តាលពីរបៀបដាំបន្លែធម្មជាតិ និងចូលរួមការចម្អិនម្ហូបអាហារ ដោយបង្កើតឲ្យមានអាហារូបត្ថម្ភសម្បូរបែបតាមរយៈការប្រើប្រាស់បន្លែក្នុងសួន។
- សួនបន្លែនៃគម្រោងម្ហូបអាហារមានគោលដៅលើកកម្ពស់ភាពសម្បូរបែបនៃម្ហូបអាហារក្នុងសហគមន៍គោលដៅនានា តាមរយៈការបង្កើនលទ្ធភាពក្នុងការទទួលបាននូវបន្លែ និងផ្លែឈើគ្រប់គ្រាន់។

### សមិទ្ធផល

| | | |
|---|---|---|
| • *បង្កើតសួនបន្លែ* | : | *២១* |



*អេីនខ្ល ថតរូបជាមួយដៃគូការងារ ក្នុងសួនបន្លែរបស់ពួកគេ*




*ផិហ្គិន ថតរូបជាមួយគ្រូដៃគូ ក្នុងបណ្ណាល័យសាលា*

## ការអភិវឌ្ឍធនធានតាមសាលា

- អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាធ្វើការជាមួយដៃគូសហគមន៍ដើម្បីលើកកម្ពស់និងតុបតែងឡើងវិញនូវមជ្ឈមណ្ឌលធនធាននៅតាមសាលារៀនរបស់ពួកគេ។ គម្រោងទាំងនេះក៏បណ្តុះបណ្តាលគ្រូបង្រៀននិងបុគ្គលិកសិក្សាផងដែរ អំពីវិធីដែលអាចប្រើប្រាស់ធនធានទាំងនោះឲ្យអស់ពីលទ្ធភាពនិងមានប្រសិទ្ធភាព។
- គម្រោងអភិវឌ្ឍន៍ធនធានរួមមានការបន្ថែមសៀវភៅសម្រាប់សិក្សា កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងរូបភាព និងសម្ភារៈឧបទេសនានាសម្រាប់ការបង្រៀន។ គម្រោងនេះក៏រាប់បញ្ចូលទាំងការជួសជុលថ្នាក់រៀននិងបណ្ណាល័យថ្មីដើម្បីកសាងបរិស្ថានល្អស្អាតងាយស្រួលដល់ការរៀនសូត្រ។
- គម្រោងអភិវឌ្ឍន៍ធនធានផ្តោតទៅលើការលើកកម្ពស់ការអប់រំតាមរយៈការផ្តល់លទ្ធភាពអាចចូលទៅមើលឯកសារសម្រាប់ការសិក្សារៀនសូត្រនិងការបញ្ចូលឯកសារទាំងនេះទៅក្នុងថ្នាក់រៀន។

### សមិទ្ធផល

| | | |
|---|---|---|
| • *ជួសជុលបណ្ណាល័យ* | : | *៥* |
| • *ជួសជុលបន្ទប់កុំព្យូទ័រ* | : | *៤* |
| • *ទិញសៀវភៅដាក់បណ្ណាល័យសាលា* | : | *២,០០០+* |
| • *ទិញកុំព្យូទ័រថ្មី* | : | *៣០* |

# ដំណើររឿងជោគជ័យលើផ្នែកជំនួយគម្រោងតូចៗ

## សួនបន្លែរបស់គ្រួសារខ្ញុំ

*អ្នកស្ម័គ្រចិត្ត ម៉ាឌី ឡាប៉ាត្រា និងក្រុមគ្រួសារខ្មែររបស់គាត់*
*ខេត្តពោធិ៍សាត់*

លោកពូ សំ មៅ និងអ្នកមីង ហាន សួន ដែលជាឪពុក និងម្តាយរបស់គ្រួសារមួយដែលបានផ្តល់កន្លែងស្នាក់នៅដល់អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាម្នាក់ក្នុងផ្ទះរបស់ខ្លួន មានបំណងចង់កសាងសួនបន្លែមួយ តែពួកគាត់មិនដឹងថាត្រូវសង់ដោយរបៀបណា។ រួមគ្នាជាមួយអ្នកស្ម័គ្រចិត្តភីសខ័រកម្ពុជាពួកគេបានចូលរួមវគ្គបណ្តុះបណ្តាលរបស់ភ្នាក់ងារភីសខ័រកម្ពុជាអំពីវិធីធ្វើសួនបន្លែដើម្បីលើកកម្ពស់អាហារូបត្ថម្ភ។ ក្នុងអំឡុងវគ្គបណ្តុះបណ្តាលនេះ ពូមៅ និងមីងសួន ទទួលបានព័ត៌មានពេញលេញពីវគ្គបណ្តុះបណ្តាល ហើយ មីងសួន បានកត់ត្រាយ៉ាងយកចិត្តទុកដាក់។ ៦ខែក្រោយពីវគ្គបណ្តុះបណ្តាលចប់ សួនបន្លែមួយបានរីកយ៉ាងស្រស់បំព្រង និងលូតលាស់នៅផ្ទះរបស់ពួកគាត់។



ម៉ាឌី និងពូមៅដែលជាពុកខ្មែររបស់គាត់ ធ្វើជីរធម្មជាតិពីអង្កាម

> “សួនបន្លែរបស់យើងមាននិរន្តរភាពណាស់ ព្រោះយើងបានហាលគ្រាប់ពូជដែលយើងបេះទុកសម្រាប់ធ្វើពូជ យើងបានលក់បន្លែខ្លះដែលសល់ពីការហូបចុក ហើយយើងលែងទិញបន្លែពីផ្សារទៀតហើយ។
> – ម៉ាឌី”

មីង សួន និងម្តាយរបស់គាត់មានជំងឺលើសឈាម ម្លោះហើយ បន្លែគឺជាអាហារដ៏ល្អបំផុត។ ពួកគេត្រូវទិញបន្លែពីផ្សារ។ ចាប់តាំងពីចូលរួមវគ្គបណ្តុះបណ្តាលរួចមក គ្រួសារនេះតែងដាំបន្លែក្នុងសួនរបស់ខ្លួន និងបន្ថែមដាំបន្លែច្រើនមុខទៀត។ មីងសួន បានដឹងអំពីក្រុមអាហារចំនួនបីប្រភេទ និងដឹងពីរបៀបចម្អិនអាហារដើម្បីទទួលបាននូវសុខភាពល្អតាមរយៈការប្រើប្រាស់អំបិលតិចជាងមុន និងគ្មានប៊ីចេង។ ពូមៅ និង មីងសួន យល់អំពីអត្ថប្រយោជន៍នៃការញ៉ាំបន្លែ និងយល់ដឹងថាហេតុអ្វីបានជាវីតាមីនមានសារៈសំខាន់ធ្វើឲ្យមានសុខភាពល្អ។ សម្ពាធឈាមរបស់ មីងសួន បានថយចុះ ហើយពេលនេះគាត់គឺជាធនធានមួយនៅក្នុងសហគមន៍ និងបានបង្រៀនអ្នកផ្សេងទៀតពីរបៀបបន្ថែមបន្លែច្រើនមុខចូលក្នុងអាហារប្រចាំថ្ងៃឲ្យមានប្រសិទ្ធិភាព។ ពូមៅ និង មីងសួន បានចែករំលែកបន្លែដែលខ្លួនដាំបានជាមួយសហគមន៍។ មិត្តភក្តិ និងអ្នកជិតខាងបានមកលេង និងសួរនាំអំពីរបៀបដាំបន្លែ រួចរៀនពីគ្រួសារមួយនេះ។

ពូមៅ បានអង្គុយលេងជាមួយមិត្តភក្តិ និងអ្នកជិតខាងទាំងនោះ រួចយកសៀវភៅដែលគាត់ទទួលបានពីវគ្គបណ្តុះបណ្តាល ហើយគាត់បានបង្រៀនពួកគេអំពីវិធីបង្កើតសួនច្បារនៅតាមផ្ទះ។ សួនច្បារថ្មីៗពីរបីកន្លែងលេចចេញជារូបរាងក្នុងសហគមន៍ ដែលជាលទ្ធផលនៃគំរូសួនបន្លែដែលបានបង្កើតឡើងតំបូង។

គ្រួសារនេះបានលក់បន្លែដែលលើសពីតម្រូវការនៅហាងមីងរបស់គាត់។ អ្នកជិតខាងតែងតែមកសួរនាំរកទិញបន្លែពីសួនផ្ទាល់តែម្តង។ ពូមៅ និង មីងសួន មានមោទនភាពចំពោះសួនបន្លែរបស់ខ្លួន និងបន្លែធម្មជាតិដោយគ្មានជាតិគីមីដែលខ្លួនបានផលិតព្រោះប្រជាជនកម្ពុជាកំពុងមានការព្រួយបារម្ភអំពីប្រភពបន្លែ និងផ្លែឈើដែលនាំចូលមក និងចាប់ផ្តើមឲ្យតម្លៃបន្លែគ្មានជាតិគីមី។

សួនបន្លែនេះមាននិរន្តរភាព។ គ្រួសារនេះហាលគ្រាប់បន្លែដែលបេះបានសម្រាប់ធ្វើពូជ លក់បន្លែដែលលើសពីតម្រូវការ និងមិនចាំបាច់ទិញបន្លែពីទីផ្សារទៀតទេ។ ពួកគេអាចថែមទាំងសន្សំលុយសម្រាប់ទុកឲ្យកូនស្រីទៅរៀននៅមហាវិទ្យាល័យដោយសារតែប្រាក់ចំណូលដែលបានមកពីសួនបន្លែនេះ។

គ្រួសារ និង ម៉ាឌី បាននាំគ្នាដាំបន្លែឡើងវិញក្នុងសួនបន្លែជាច្រើនដង និងបានបរិភោគបន្លែដែលដាំនៅផ្ទះរៀងរាល់ពេលទាំងអស់។ ទំនុកចិត្ត និងភាពជាអ្នកដឹកនាំរបស់ ពូមៅ និង មីងសួន នឹងជួយគាំទ្រដល់សហគមន៍ឲ្យមានដោយសុខភាពល្អនាពេលអនាគត។



ម៉ាឌី និងប្អូនស្រី និងអ្នកមីងសួនត្រូវជាម្តាយខ្មែរ នៅក្នុងសួនបន្លែផ្ទះរបស់គាត់

# ដំណើររឿងជោគជ័យលើផ្នែកជំនួយគម្រោងតូចៗ

## បង្គន់អនាម័យសម្រាប់ការអប់រំប្រកបដោយសមធម៌

*អ្នកស្ម័គ្រចិត្ត លីនស៊ី បោនីក និងលោកនាយកសាលា ឃឹម សុខុម*
*ខេត្តត្បូងឃ្មុំ*

វិទ្យាល័យមួយក្នុងខេត្តត្បូងឃ្មុំមានបន្ទប់ទឹកដែលអាចប្រើប្រាស់បានតែពីរគត់សម្រាប់ សិស្សចំនួនពីរពាន់នាក់មកពីភូមិចំនួន១៥។ ដោយសារតែប្រភពទឹកមិនទៀងទាត់ បន្ទប់ទឹកមួយចំនួនដែលត្រូវបានគាំងដំណើរជាង១០ឆ្នាំមកហើយធ្វើឲ្យមិនអាចប្រើប្រាស់ទៀតបាន។ សិស្សបានបាត់បង់ពេលវេលាសិក្សារៀនដោយសារការប្រើប្រាស់បន្ទប់ទឹក។ សិស្សស្រីមានចំនួនត្រឹមតែ៩%ប៉ុណ្ណោះដែលមានអារម្មណ៍ថាងាយស្រួលប្រើប្រាស់បង្គន់នៅសាលារៀន។ ស្ថានភាពនេះ មានភាពលំបាកពន់ពេកដែលធ្វើឲ្យសិស្សត្រូវចេញពីបរិវេណសាលា នៅពេលណាពួកគេត្រូវប្រើប្រាស់បង្គន់។

> *“ឥឡូវនេះ សិស្សានុសិស្សហាក់បីដូចជាសប្បាយចិត្តច្រើនជាងមុន ដោយសារតែពួកគេមានកន្លែងស្អាតសម្រាប់ចូលទៅកាន់បន្ទប់ទឹក និងធ្វើការលាងសម្អាត។*
>
> *– លោកនាយក ឃឹម សុខុម”*

នាយកវិទ្យាល័យ គ្រូបង្រៀន និងអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាម្នាក់ឈ្មោះ លីនស៊ី បោនីក បានសហការលើកគម្រោងមួយដើម្បីលើកកម្ពស់បញ្ហាបរិក្ខារអនាម័យ និងសុខុមាលភាពនៅសាលារៀនរបស់ពួកគាត់។ គម្រោងនេះទទួលបានថវិកាចំនួន៩៦៥៧ដុល្លាពីមូលនិធិ និងទទួលបានថវិកាចំនួន២២១០ដុល្លាពីវិភាគទានសហគមន៍។ គម្រោងដំបូងគឺត្រូវជួសជុលបន្ទប់ទឹកចាស់ៗចំនួនពីរ និងសាងសង់បន្ទប់ទឹកថ្មីចំនួនបួន និងកន្លែងលាងដៃចំនួនបួនកន្លែង។ ដោយសារតែមានការគាំទ្រដ៏លើសលប់ពីសំណាក់សហគមន៍


*បន្ទប់ទឹក សាងសង់សម្រាប់សិស្សសាលា*

និងចម្លើយវិជ្ជមានពីសិស្សានុសិស្ស គម្រោងបានកសាងបន្ទប់ទឹកពីរបន្ថែមទៀត និងកន្លែងលាងដៃពីរកន្លែងបន្ថែមទៀតដោយសាងសង់បន្ទប់ទឹកទាំងអស់ចំនួន១០ បំពាក់ដោយប្រព័ន្ធទឹកស្អាតនិងបង្កើតកន្លែងលាងដៃថ្មីៗចំនួន៦កន្លែងទៀតក្នុងបរិវេណវិទ្យាល័យនេះ។ ជាលទ្ធផលនៃការអនុវត្តគម្រោងនេះ សិស្សចំនួន៨០%នៃសាលាដែលមានសិស្សពីរពាន់នាក់បានរាយការណ៍ថាបានចំណាយពេលតិចជាងមុនដើម្បីទៅប្រើប្រាស់បន្ទប់ទឹក។

បន្ថែមលើនេះ សិស្សស្រីចំនួន១៦៦នាក់បានទទួលការអប់រំអំពីការគ្រប់គ្រងអនាម័យពេលមានរដូវ ក្នុងនោះអ្នកចូលរួមសិក្ខាសាលាចំនួន១០០% បានយល់ដឹងជាក់ច្បាស់ពីការភ័ន្តច្រឡំកន្លងមកអំពីសុខភាពពេលមានរដូវក្រោយពីវគ្គសិក្ខាសាលាដែលប្រើពេលមួយថ្ងៃពេញ។ ប្រធានថ្នាក់ច្រើនរូបដែលទទួលបានការបណ្តុះបណ្តាលពីភ្នាក់ងារភីសខ័រកម្ពុជាបានជួយសហការ និងសម្របសម្រួលសិក្ខាសាលា ដែលផ្តល់ឱកាសដល់ពួកគេក្នុងការអនុវត្តជំនាញភាពជាអ្នកដឹកនាំរបស់ពួកគេ។


*អ្នកគ្រូពន្យល់អំពីការរក្សាអនាម័យពេលមានរដូវ*

# បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ

## គ្រួសារខ្មែររបស់ខ្ញុំសុំខ្ញុំធ្វើកូនចិញ្ចឹម

*ដោយ៖ អ្នកស្ម័គ្រចិត្ត ការីណា លីចមែន*



ការីណា និងគ្រួសារខ្មែររបស់គាត់

ពេលដែលខ្ញុំឈានជើងចុះពីរថយន្តដើម្បីជួបជាមួយគ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំកាលពីគ្រាដំបូង ពួកគេទទួលរាក់ទាក់ខ្ញុំដោយការញញឹមយ៉ាងស្រស់ស្រាយ និងមានចិត្តទូលាយ។ ចាប់ពីថ្ងៃទីមួយមក ពួកគាត់ធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវបានស្វាគមន៍ និងក្លាយជាសាច់ញាតិម្នាក់របស់គ្រួសារគាត់ផងដែរ។ ពេញមួយឆ្នាំមានរឿងរ៉ាវជាច្រើនបានកើតឡើងដូចជា៖ បញ្ហាដែលត្រូវដោះស្រាយជាច្រើនក្នុងគ្រួសារ មរណភាពនៅក្នុងសហគមន៍ ពិធីមង្គលការ ទារកចាប់កំណើត។ រឿងរ៉ាវទាំងនេះធ្វើឲ្យខ្ញុំមានអារម្មណ៍ថាមានកំហុសព្រោះខ្ញុំហាក់បីដូចជាបន្ថែមការរំខានដល់ពួកគេទៅវិញ។ ប៉ុន្តែ គ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំបានផ្តល់ឲ្យខ្ញុំនូវក្តីមេត្តា និង ភាពអត់ធ្មត់ទោះមានរឿងល្អ និងមិនល្អខ្លះក៏ដោយ។ ពួកគេចាត់ទុកខ្ញុំជាសមាជិកម្នាក់របស់ពួកគេ។ ពួកគេមិនដែលភ្លេចក្រើនរំឭកខ្ញុំថា ខ្ញុំជាកូនទីបួននៅក្នុងគ្រួសារឡើយ ពួកគេជាឪពុកម្តាយចិញ្ចឹមរបស់ខ្ញុំ ហើយខ្ញុំជាកូនរបស់ពួកគាត់។ ពួកគេធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំជាផ្នែកមួយនៃគ្រួសារ។ ក្នុងអារម្មណ៍សង្ស័យខ្លួនឯង ខ្ញុំបានឮម្តាយដែលជាម្ចាស់ផ្ទះរបស់ខ្ញុំនិយាយការពារខ្ញុំពីមនុស្សគ្រប់គ្នាដែលមកសួរនាំខ្ញុំពីសមត្ថភាពនិយាយភាសាខ្មែររបស់ខ្ញុំ ការហូបម្ហូបខ្មែរ និងការរស់នៅទីនេះ។ បងប្អូនស្រីម្ចាស់ផ្ទះទាំងបីនាក់របស់ខ្ញុំបានជួយខ្ញុំជ្រើសរើសសម្លៀកបំពាក់សម្រាប់ពិធីមង្គលការពិសេសៗ ហើយទោះបីជាខ្ញុំជ្រើសរើសសម្លៀកបំពាក់អ្វីក៏ដោយ គាត់ឲ្យខ្ញុំខ្ចីអ្វីៗគ្រប់យ៉ាងដែលពួកគាត់មាន គាត់បានធ្វើសក់ឲ្យខ្ញុំ ផាត់មុខឲ្យខ្ញុំ ឲ្យស្បែកជើងខ្ញុំខ្ចី ឲ្យគ្រឿងអលង្ការខ្ញុំពាក់ និងឲ្យកាបូបដៃខ្ញុំយួរ។

ពួកគេបង្រៀនខ្ញុំថា ក្តីស្រលាញ់មានទំហំធំជាងភាសា និងវប្បធម៌ និងបង្រៀនខ្ញុំថា ក្តីស្រលាញ់ទាំងនោះត្រូវបានផ្តល់ឲ្យមកខ្ញុំ និងទទួលតាមរយៈការចាប់កាន់ដៃនៅពេលដែលពួកគេជួបខ្ញុំ ស្នាមញញឹម និងសំណើចនៅពេលដែលពួកគេហៅឈ្មោះខ្ញុំ និងសំណួរដែលតែងតែសួរមកខ្ញុំថា ខ្ញុំញ៉ាំបាយហើយឬនៅ ខ្ញុំកំពុងទៅណា ខ្ញុំសប្បាយចិត្តឬអត់។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងពន្លឹកដែលគ្រួសារនោះបានឈានមួយជំហានទទួលយកអ្វីដែលមិនធ្លាប់ស្គាល់ពីមុនមក និងអនុញ្ញាតឲ្យភ្នាក់ងារភីសខ័រកម្ពុជាដាក់អ្នកស្ម័គ្រចិត្តជនជាតិអាមេរិកាំងម្នាក់នៅផ្ទះរបស់គាត់ និងអនុញ្ញាតឲ្យរស់នៅកន្លែងអចិន្ត្រៃយ៍មួយក្នុងជីវិតរបស់ពួកគេ។ ខ្ញុំបានប្រាប់គាត់ឲ្យជួយថ្លែងអំណរគុណសហគមន៍របស់ខ្ញុំដែលបានស្វាគមន៍ទៅវិញទៅមកនិងទទួលខ្ញុំដោយភាពកក់ក្តៅ និងដឹងថា បទពិសោធន៍ជាមួយភ្នាក់ងារភីសខ័ររបស់ខ្ញុំនឹងមិនដូចគ្នាទេប្រសិនបើគ្មានគ្រួសារ និង សហគមន៍នោះ។

## ខ្ញុំស្រលាញ់គ្រួសារម្ចាស់ផ្ទះខ្ញុំដូចគ្រួសារបង្កើតរបស់ខ្ញុំអញ្ចឹងដែរ

*ដោយ៖ អ្នកស្ម័គ្រចិត្ត លា វុដ*

ពេលមើលត្រលប់ថយក្រោយវិញកាលពីជាងមួយឆ្នាំមុន ទំនាក់ទំនងរវាងខ្ញុំនឹងគ្រួសារចិញ្ចឹមរបស់ខ្ញុំក្លាយជាអ្វីមួយដែលខ្ញុំម៉ានមាទនភាព និងរីករាយនូវអ្វីដែលខ្ញុំបានធ្វើ។



លា និងក្រុមគ្រួសារខ្មែររបស់គាត់

នេះគឺជាឆ្នាំដំបូងរបស់គ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំដែលបានធ្វើការជាមួយភ្នាក់ងារភីសខ័រ ហើយយើងទាំងអស់គ្នាមិនបានគិតថាតើអ្វីនឹងកើតមាននោះទេ។ យើងបានជួបប្រទះនូវឱកាសឆ្កាំឆ្កងមួយចំនួន ប៉ុន្តែពួកគេបានធ្វើកិច្ចការជាច្រើនដើម្បីធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវបានស្វាគមន៍ទាំងនៅផ្ទះនិងនៅសហគមន៍របស់ពួកគេតាមរយៈការចំណាយពេលជាច្រើនដើម្បីពន្យល់ប្រាប់ខ្ញុំអំពីសារៈសំខាន់ និងតម្លៃនៃវប្បធម៌ខ្មែរ ព្រមទាំងរឿងរ៉ាវផ្ទាល់ខ្លួន និងបទពិសោធន៍ផ្ទាល់របស់ពួកគេផងដែរ។

ខ្ញុំស្រលាញ់គ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំដូចគ្រួសារបង្កើតរបស់ខ្ញុំដែរ ហើយខ្ញុំមិនអាចស្រមើស្រមៃឃើញថា ខ្ញុំអាចទទួលបានបទពិសោធន៍ទាំងនេះទេ ប្រសិនបើគ្មានពួកគាត់។ ឪពុកម្តាយខ្មែររបស់ខ្ញុំចាត់ទុកខ្ញុំដូចជា "កូនស្រី" របស់គាត់ដែរ។ ខ្ញុំមានឱកាសនឹងធ្វើដំណើរជាមួយពួកគាត់ទៅស្រុកកំណើតរបស់គាត់នៅខេត្តជិតគ្នានោះដើម្បីចូលរួមមង្គលការ និងបុណ្យសពផ្សេងៗ និងដើម្បីជួបជាមួយសាច់ញាតិរបស់ពួកគាត់នៅទីនោះ។ ការនិយាយពាក្យថា "លា" ទៅកាន់ពួកគាត់ គឺជាពាក្យពិបាកនិយាយជាទីបំផុតនៅពេលដែលខ្ញុំត្រូវចាកចេញពីសហគមន៍នេះ។

# បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ

## គ្រួសារខ្មែររបស់ខ្ញុំនឹងស្ថិតនៅក្នុងចិត្តខ្ញុំជារៀងរហូត

*ដោយៈ អ្នកស្ម័គ្រចិត្ត សាម៉ែនថា ហុកខេនសុន*



សាមេនថា និងក្រុមគ្រួសារខ្មែររបស់គាត់

កាលពីដំបូង ខ្ញុំមានអារម្មណ៍ថា គ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំគឺជាអ្វីមួយដែលលំបាកបំផុតសម្រាប់ការងាររបស់ខ្ញុំជាអ្នកស្ម័គ្រចិត្តកីឡាសខ័រ ។ មានរឿងគួរឲ្យលំបាកជាច្រើន ដូចជា បញ្ហាភាសា ភាពផ្ទាំផ្គង និងការមិនយល់គ្នា។

ប៉ុន្តែពេលវេលាចេះតែកន្លងទៅ ការព្យាយាមទាំងនេះកើតឡើងកាន់តែតិចទៅៗ និងរង្វើលទៅៗ រហូតដល់ថ្ងៃមួយដែលខ្ញុំស្វែងយល់ឃើញថាគ្មានការលំបាកណាមួយដែលកើតឡើងរហូតនោះទេ។ យើងចាប់ផ្តើមមានភាពស៊ីសង្វាក់គ្នាយ៉ាងអស្ចារ្យ និងដោយគ្មានការគ្រោងទុក។ រំពេចនោះ ខ្ញុំអាចនិយាយទៅកាន់ពួកគាត់អំពីអ្វីគ្រប់យ៉ាងដែលធ្លាប់តែរំខានខ្ញុំ ហើយ ពួកគាត់ចាប់ផ្តើមយល់បានល្អជាងអ្នកផ្សេងទៀត ពីភាពស្មុគស្មាញការងាររបស់ខ្ញុំនៅក្នុងសហាគមន៍។

ពួកគាត់ស្គាល់ពីទីកន្លែង ស្គាល់ពីចរិត និងអតីតកាលរបស់សហាគមន៍។ អ្វីដែលធ្វើឲ្យខ្ញុំរំភើបចិត្តជាងគេទៅទៀតនោះគឺការដែលម្តាយខ្មែររបស់ខ្ញុំស្គាល់ខ្ញុំយ៉ាងឆាប់រហ័សដូចជាគាត់ស្គាល់អ្នកផ្សេងទៀតដែរ។ គាត់ចាប់ផ្តើមនិយាយដាក់ខ្ញុំដូចម្តាយបង្កើតរបស់ខ្ញុំនៅអាមេរិកដែរ ដូចជាថា”ខ្ញុំភ្លេចគ្រប់យ៉ាង!” ឬក៏ថា “ខ្ញុំចូលចិត្តធ្វើអ្វីដោយខ្លួនឯង! “។ ខ្ញុំតែងតែគិតថា “ប្រសិនបើគ្រួសារខ្មែរ និងគ្រួសារអាមេរិកាំងរបស់ខ្ញុំចេះនិយាយភាសាដូចគ្នា ពួកគេនឹងនិយាយគ្នាអំពីរឿងរបស់ខ្ញុំ ហើយសើចដាក់ខ្ញុំជាមិនខាន”។

ក្រោយពីរស់នៅជាមួយគ្រួសារម្ចាស់ផ្ទះអស់រយៈពេលជាងមួយឆ្នាំ ខ្ញុំដឹងពីទំហំនៃការស្គាល់គ្នា និងទំហំនៃក្តីស្រឡាញ់។ ខ្ញុំដឹងថា យើងនឹងក្លាយជាផ្នែកមួយនៃជីវិតរបស់យើងជារៀងរហូត។ “កុំភ្លេចទូរស័ព្ទមកលេងយើងមួយសប្តាហ៍ម្តងនៅពេលឯងត្រលប់ទៅអាមេរិកវិញ!”។ ខ្ញុំនឹងមិនអាចបំភ្លេចពួកគាត់បានទេ។ ទំនាក់ទំនងខ្ញុំជាមួយគ្រួសារខ្មែរបានក្លាយជាផ្នែកដ៏ពិសេសមួយនៃការងារស្ម័គ្រចិត្តរបស់ខ្ញុំនៅប្រទេសកម្ពុជា។

## ខ្ញុំទទួលបាននូវក្តីស្រលាញ់ជាច្រើនពីគ្រួសារខ្មែរដែលខ្ញុំរស់នៅជាមួយ

*ដោយៈ អ្នកស្ម័គ្រចិត្ត សានីហ្គ័រ ស្មីត*

ខ្ញុំមានអារម្មណ៍អន្ទះសារពេលត្រូវជួបគ្រួសារខ្មែរដែលខ្ញុំត្រូវនៅជាមួយ។ ខ្ញុំព្រួយខ្លាចពួកគេមិនចូលចិត្តខ្ញុំដោយសារតែយើងមានប្រវត្តិជីវិតខុសគ្នា។ ពួកគេយល់ព្រមនឹងទទួលយកមនុស្សចម្លែកម្នាក់មកនៅជាមួយអស់រយៈពេលពីរឆ្នាំ។ មនុស្សចម្លែកម្នាក់ដែលមានប្រវត្តិផ្សេងគ្នារួមទាំងជាតិសាសនា ជំនឿវប្បធម៌ ភាសា និងបែបផែនគ្រួសារ។



សានីហ្គ័រ និងក្រុមគ្រួសារខ្មែររបស់គាត់

ជាភ័ព្វសំណាង ខ្ញុំទទួលបាននូវសេចក្តីស្រលាញ់ និងការពេញចិត្តយ៉ាងច្រើនពីគ្រួសារម្ចាស់ផ្ទះដែលខ្ញុំនៅជាមួយ។ ភាពអត់ធ្មត់ដែលពួកគាត់មានចំពោះខ្ញុំ ជាពិសេសភាពអត់ធ្មត់ជាមួយខ្ញុំពេលរៀនភាសាខ្មែរ លើកទឹកចិត្តខ្ញុំឲ្យប្រឹងរៀនខ្លួនឯងឲ្យខ្លាំងជាងមុន។ ក្នុងនាមជាស្ត្រីស្បែកខ្មៅមួយរូប វាពិតជាពិបាករស់នៅណាស់ក្នុងប្រទេសកម្ពុជា។ ពេលដែលខ្ញុំសម្ភាសជាមួយភ្នាក់ងារកីឡាសខ័រកម្ពុជា ខ្ញុំបានជូនដំណឹងទៅបុគ្គលិកខ្មែរថា ខ្ញុំចង់បានគ្រួសារមួយដើម្បីរស់នៅជាមួយហើយគ្រួសារនោះអាចយល់ពីស្ថានភាពនៃសម្បុរស្បែករបស់ខ្ញុំ។ និយាយតាមត្រង់ទៅ ខ្ញុំមានអារម្មណ៍មិនស្រឡះសោះដោយខ្លាចសំណើរបស់ខ្ញុំមិនត្រូវបានស្វាគមន៍ តែខ្ញុំរំពឹងលើព្រេងវាសនាទៅចុះ។រហូតមកដល់ថ្ងៃនេះ ខ្ញុំមានគ្រួសារមួយដែលបង្ហាញខ្ញុំនូវសេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌ ទោះបីជាយើងមានភាពខុសគ្នាយ៉ាងណាក៏ដោយ។ នៅក្នុងសហាគមន៍គេគិតថា វាមិនអីទេដែលត្រូវប្រាប់ខ្ញុំឲ្យខាត់ស្បែកឲ្យស ហើយប្រាប់ខ្ញុំថាស្បែកខ្ញុំខ្មៅ ហើយអាក្រក់ជាដើម។ នៅពេលខ្ញុំនិយាយប្រាប់គ្រួសារម្ចាស់ផ្ទះអំពីអារម្មណ៍បែបនេះ ពួកគាត់តែងតែស្តាប់ខ្ញុំ និងផ្តល់ដំបូន្មានឲ្យខ្ញុំ និងបញ្ជាក់យ៉ាងម៉ឺងម៉ាត់ពីសេចក្តីស្រលាញ់របស់ពួកគាត់ចំពោះខ្ញុំ។ ក្តីស្រលាញ់ដែលពួកគាត់អោយខ្ញុំគឺគ្រប់គ្រាន់ ហើយពួកគាត់ទាំងអស់គ្នាជាគ្រួសាររបស់ខ្ញុំជារៀងរហូត។ អនុស្សាវរីយ៍ដែលខ្ញុំមាននឹងស្ថិតនៅជាមួយខ្ញុំអស់មួយជីវិត។

# បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ

## *រស់នៅជាមួយគ្រួសារខ្មែរ គឺជាការពេញចិត្ត និងជាដំណើរជីវិតដ៏អស្ចារ្យ*

*ដោយ៖ អ្នកស្ម័គ្រចិត្ត ប្រាយអ៊ិន ដូណាថាលី*



ប្រាយអ៊ិន និងគ្រួសារខ្មែររបស់គាត់

*ពេលដែលខ្ញុំបានជួប និងរស់នៅជាមួយគ្រួសារខ្មែររបស់ខ្ញុំ ខ្ញុំមានអារម្មណ៍មិនអាចបំភ្លេចបាន។ ខ្ញុំមានការត្រៀមទុកច្រើន និងអារម្មណ៍មិនស្ងប់សោះមុននឹងជួបពួកគាត់។ ខ្ញុំមានចម្ងល់ជាច្រើនអំពីការទំនាក់ទំនង វប្បធម៌ និងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ ដែលចេះតែវិលវល់រហូត។ នៅពេលខ្ញុំស្រស់ស្រូបអាហារពេលល្ងាចជាមួយគ្រួសារម្ចាស់ផ្ទះជាលើកដំបូង បានបន្សល់ធ្វើអោយខ្ញុំមានអារម្មណ៍ស្រពិចស្រពិល និងឆ្ងាំឆ្គង និងមិនប្រាកដប្រជាទាល់តែសោះ។ ខ្ញុំសួរខ្លួនឯងថា "តើខ្ញុំអាចបកប្រែគ្រប់យ៉ាងដែលពួកគាត់និយាយដោយវិធីណាទៅ ជាពិសេសជាមួយជីដូនដែលជាសមាជិកគ្រួសារម្ចាស់ផ្ទះនោះ"? ដូចដែលអ្នកស្ម័គ្រចិត្តជាច្រើនផ្សេងទៀតបានដឹងហើយ វាគឺជាជំហានមួយម្តងៗ ត្រចៀករបស់ខ្ញុំសម្របទៅនឹងសម្លេងដដែលៗ ហើយជាច្រើនថ្ងៃក្រោយមក អ្វីៗប្រែជាស្រួលជាងមុន។ ស្នាមញញឹមដ៏កក់ក្តៅ និងការយកចិត្តទុកដាក់របស់អ្នករាល់គ្នាបានស្វាគមន៍ខ្ញុំចូលក្នុងពិភពរបស់ពួកគាត់។ ភាពស្ងាត់ស្ងៀម ដែលពីមុនប្រៀបដូចជាមនុស្សគរ បានប្រែក្លាយទៅភាពកក់ក្តៅប្រកបដោយការស្វាគមន៍។ ចម្ងល់ និងភាពឆ្គាំឆ្គងដែលធ្លាប់ធ្វើឲ្យខ្ញុំមិនមានអារម្មណ៍សុខស្រួលបានចាកចេញពីខ្លួនខ្ញុំយ៉ាងលឿនដោយសារតែការយកចិត្តទុកដាក់ និងសេចក្តីស្រលាញ់របស់គ្រួសារម្ចាស់ផ្ទះ។*

*ថ្ងៃនេះ ខ្ញុំប្រហែលជាមិនដឹងស្ថិតនៅទីណាទេប្រសិនបើគ្មានគ្រួសារខ្មែរម្ចាស់ផ្ទះខ្ញុំនោះ។ ម្តាយដែលជាម្ចាស់ផ្ទះគឺជាមនុស្សគំរូសម្រាប់ខ្ញុំ។ គាត់គឺជាអ្នកមើលថែទាំកូនបីនាក់របស់គាត់ ចិញ្ចឹមបីបាច់កូនទាំងបីឲ្យចេះគោរពចាស់ទុំ និងមានសុខភាពល្អ។គាត់តែងតែហៅខ្ញុំឲ្យជួយដាំស្ល ឬជួយបេះបន្លែ បង្កើតបានជាទីកន្លែងដ៏មានផាសុកភាពមួយក្នុងបរិយាកាសដាំស្ល។ ខ្ញុំអាចមើលឃើញថា ការមានខ្ញុំជាផ្នែកមួយនៃជីវិតរបស់គាត់ពិតជាមានសារៈសំខាន់ណាស់សម្រាប់គាត់។ រាល់ម្ហូបដែលគាត់ចំអិនមានភាពប្លែកៗ និងពិសេស (ខ្ញុំជាអ្នកចូលចិត្តសម្លរកកូរ)។ គាត់ផ្តល់នូវ ការយកចិត្តទុកដាក់ និងក្តីស្រលាញ់ជាច្រើននៅក្នុងម្ហូបអាហារដែលគាត់ចំអិន "ដើម្បីចិញ្ចឹមបីបាច់ និងផ្តល់កម្លាំងកំហែងដល់កូនប្រុសទាំងបួនរបស់គាត់ហើយពេលនេះ"។*

*ក្តីស្រលាញ់ និងក្តីមេត្តាធម៌គឺជាចំណុចសំខាន់បំផុតក្នុងអំឡុងពេលដ៏លំបាកផ្ទាល់ខ្លួនសម្រាប់ខ្ញុំ។ ជាអកុសល ក្នុងអំឡុងពេលនៃការបម្រើការងារជាមួយភ្នាក់ងារភីសខ័រកម្ពុជា ជីដូនរបស់ខ្ញុំនៅអាមេរិកបានទទួលមរណភាព។ ដោយក្តីមេត្តាធម៌ ម្តាយដែលជាម្ចាស់ផ្ទះបានធ្វើពិធីតូចមួយនៅវត្តដើម្បីគោរពវិញ្ញាណក្ខន្ធដល់ជីដូនរបស់ខ្ញុំ។ នេះជាសកម្មភាពដ៏ប្រពៃ និងជ្រាលជ្រៅជាពន់ពេក។ អ្នកជិតខាង លោកគ្រូ អ្នកគ្រូ ដូនជី និងជីដូនចាស់ៗជាច្រើនទៀត និងប្អូនប្រុសបានចូលរួមពិធីគោរពវិញ្ញាណក្ខន្ធនេះ។ ថាមពលពិតជាអស្ចារ្យមែន។ ទោះបីជាខ្ញុំយំនៅពេលនោះក៏ដោយ ខ្ញុំចាប់ផ្តើមមានអារម្មណ៍កក់ក្តៅ និងអំណរអរគុណ និងមិនឯកោរទេ។ ទោះបីពេលនោះជាផ្នែកនៃអារម្មណ៍ដ៏លំបាកបំផុតមួយនៃកិច្ចការងាររបស់ខ្ញុំក៏ដោយពេលនោះគឺជាផ្នែកដ៏ល្អបំផុតនៃកិច្ចការងាររបស់ខ្ញុំ។ នៅពេលខ្ញុំសម្លឹងមើលទៅក្រោយ ខ្ញុំសឹងតែមិនជឿថា គ្រួសារមួយដែលខ្ញុំបានជួបមួយឆ្នាំកន្លងទៅបង្កើតបានជាឱកាសដ៏ល្អសម្រាប់ខ្ញុំដូច្នេះសោះ។*

*រស់នៅជាមួយគ្រួសារម្ចាស់ផ្ទះខ្មែរគឺជាការពេញចិត្ត និងជាដំណើរជីវិតមួយដ៏អស្ចារ្យ។ ខ្ញុំមិនគិតថា មានវិធីអ្វីផ្សេងទៀតអាចទទួលបាននូវបទពិសោធន៍ពីជីវភាពរស់នៅរបស់នរណាម្នាក់នោះទេ។ យើងទាំងអស់គ្នា ក្នុងនាមជាអ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារភីសខ័រកម្ពុជាបានក្លាយជាផ្នែកមួយនៃជីវិតរបស់ពួកគាត់ ហើយពួកគាត់ស្វាគមន៍ពួកយើងដោយក្តីរីករាយជាទីបំផុត។*


Peace Corps
លើកកម្ពស់សន្តិភាពពិភពលោក និងកសាងមិត្តភាព
Agriculture and Health

**ព័ត៌មានទំនាក់ទំនង៖**

ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជា
ប្រអប់សំបុត្រលេខ ២៩៥៣ ភ្នំពេញ ៣ ព្រះរាជាណាចក្រកម្ពុជា
ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២២២ ៩០១
ទូរសារលេខ៖ +៨៥៥ ២៣ ២២២ ៩០៣

អ៊ីមែល៖ info@kh.peacecorps.gov
គេហទំព័រ៖ http://peacecorps.gov/cambodia

**ស្វែងរកយើងតាម៖**

cambodia.peacecorps
peacecorpscambodia
PeacecorpsCambo




Peace Corps

ភីសខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និង សាសនា របស់រដ្ឋាភិបាល សហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកម្ពស់សន្តិភាព និង មិត្តភាពរវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងៗគ្នា ។ អស់រយៈពេលជាងប្រាំទសវត្សកន្លងទៅនេះ ភ្នាក់ងារ ភីសខ័របានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសចំនួន១៩១ តាមរយៈការអនុវត្តគំរោងក្នុងវិស័យអប់រំ ការអភិវឌ្ឍអាជីវកម្ម ការការពារបរិស្ថាន កសិកម្ម និងសុខភាព ។

ខែកុម្ភៈ ឆ្នាំ២០១៨